00707725

E51/7/3

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 17 / 06 / 2011
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ :

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរួមរបស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា ទៅនឹងសេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា ស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី៖**

អាង ឧត្តម

Michael G. KARNAVAS

**សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ**

ផាត់ ពៅស៊ាង

Diana ELLIS

**សហមេធាវីរបស់លោក នួន ជា**

សុន អរុណ

Victor KOPPE

ផ្ញើជូន៖

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម ធូ មុនី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង យូ ឧត្តារ៉ា

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

00707726

ជា លាង
Andrew CAYLEY
**ក្រុមមេធាវីការពារក្តីទាំងអស់**
**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី លោកស្រី អៀង ធីរិទ្ធ និងលោក នួន ជា តាមរយៈសហមេធាវីរបស់ខ្លួននីមួយៗ ("មេធាវីការពារក្តី") និងអនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ[១] សូមដាក់ជូននូវចម្លើយតបរួមទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ ("សេចក្តីសន្និដ្ឋានរបស់ ក.ស.ព")[២]។ ចម្លើយតបនេះនឹងឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែល ក.ស.ព បានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋាននេះតែប៉ុណ្ណោះ។ ចម្លើយតបនេះនឹងមិនឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែល ក.ស.ព បានធ្វើឡើងកាលពីមុនៗ ប៉ុន្តែមិនបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋាននេះឡើយ[៣]។ មេធាវីការពារក្តីមិនបានលះបង់ចោលនូវទឡ្ហីករណ៍ដែលបានធ្វើឡើងកាលពីលើកមុនៗណាមួយ ដែលមិនត្រូវបានលើកឡើងដោយ ក.ស.ព ឡើយ។ ជាពិសេស ក្រុមមេធាវីការពារក្តី អៀង សារី មិនបានលះបង់ចោលនូវគោលជំហររបស់ខ្លួនដែលថា ក. ការណ៍នេះរំលោភលើសិទ្ធិរបស់លោក អៀង សារី ទទួលបានការសន្មតជាមុនថាគ្មានទោស ដោយការបញ្ជូនលោក អៀង សារី មកជំនុំជម្រះលើឧក្រិដ្ឋកម្មជាតិ ទោះបីជាសហចៅក្រមស៊ើបអង្កេតខ្លួនឯង មិន យល់ស្របគ្នា ថាតើ ឧក្រិដ្ឋកម្មជាតិអាចអនុវត្តបានដែរឬអត់នោះ។ ខ. ការណ៍នេះរំលោភសិទ្ធិលោក អៀង សារី ក្នុងការទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នា ក្នុងការអនុវត្តឧក្រិដ្ឋកម្មជាតិ ព្រោះតែអាជ្ញាយុកាលនៃបទល្មើសសម្រាប់ឧក្រិដ្ឋកម្មទាំងនេះត្រូវបានគេពន្យារអាជ្ញាយុកាលនៅ អវតក ប៉ុន្តែមិនបានធ្វើដូច្នេះនៅតុលាការកម្ពុជាដទៃទៀត[4]។

---

[១] សេចក្តីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E51/7 ទំព័រ ២។

[២] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E51/7/1។

[៣] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤។

[4] ក្រុមមេធាវីការពារក្តី អៀង សារី បានស្នើសុំសេចក្តីអនុញ្ញាតដើម្បីដាក់សេចក្តីសន្និដ្ឋានបន្ថែមទៅលើបញ្ហាទាំងពីរនេះ ពីព្រោះមេធាវីការពារក្តីមិនអាចបកស្រាយលើការភ័ន្តច្រលំនានា នៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយសារមេធាវីការពារក្តីត្រូវបានបង្គាប់អោយដាក់អញ្ញត្រកម្មរបស់ខ្លួននៅមុនពេលទទួលបានសាលដីកាដែលមានសំអាងហេតុ។ *សូមមើល* សំណើរបស់អៀង សារី សុំការអនុញ្ញាតដើម្បីដាក់សេចក្តីសន្និដ្ឋានបន្ថែមទៅលើអញ្ញត្រកម្មរបស់គាត់តាមវិធាន ៨៩ (ឧក្រិដ្ឋកម្មជាតិ) ចុះថ្ងៃទី ៨ មិថុនា ២០១១ ឯកសារលេខ E98។ អង្គជំនុំជម្រះសាលាដំបូង កាលមុនបានជូនដំណឹងដល់មេធាវីការពារក្តីថា ដោយហេតុថាការខាតបង់កើតចេញពីកង្វះសំអាងហេតុរបស់សាលដីកា ចេញដោយអង្គបុរេជំនុំជម្រះ សេចក្តីសន្និដ្ឋានបន្ថែមជាគោលការណ៍អាចទទួលយកបាន ប៉ុន្តែ

## I. សេចក្តីសង្ខេបនៃសេចក្តីសន្និដ្ឋានរបស់ ក.ស.៣

១. ក.ស.៣ លើកឡើងថា អាជ្ញាយុកាលរយៈពេល ១០ឆ្នាំ ជាធរមាន សម្រាប់បទល្មើសជាតិនៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មាត្រា ៣ថ្មី ត្រូវបានពន្យាររហូតដល់យ៉ាងហោចណាស់ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១[៥]។ ដូច្នេះអាជ្ញាយុកាលត្រូវបានពន្យារនៅមុនពេលការផុតកំណត់អាជ្ញាយុកាលនេះពីព្រោះ ៖

ក. “មិនមានប្រព័ន្ធតុលាការមួយដំណើរការបានទេនៅក្នុងប្រទេសកម្ពុជាដែលអាចដឹកនាំធ្វើការកាត់សេចក្តី លើជនជាប់ចោទឱ្យបានត្រឹមត្រូវទេ យ៉ាងហោចណាស់រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០”[៦]។

---

អង្គជំនុំជម្រះសាលាដំបូងនឹង ណែនាំបន្ថែមដល់មេធាវីការពារក្តី ទាក់ទងនឹងចំនួនទំព័រ និងពេលវេលាកំណត់បន្ទាប់ពីបានទទួលនូវសំអាងហេតុរបស់អង្គបុរេជំនុំជម្រះរួចមក។ *សូមមើល* សារអេឡិចត្រូនិចពី Tanya Pettay ផ្ញើរទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់កាលពីថ្ងៃទី ២៣ កុម្ភៈ ២០១១ បញ្ជាក់ពីចំនុចនានាដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំ និងការបន្ថែមចំណុចមួយចំនួនទាមទារការបញ្ជាក់បន្ថែម ហើយនិង ចម្លើយតបរបស់មន្ត្រីច្បាប់ជាន់ខ្ពស់កាលពីថ្ងៃទី ២៤ កុម្ភៈ ២០១១។ បន្ទាប់មានការចេញនូវសំអាងហេតុនៃសាលដីការបស់អង្គបុរេជំនុំជម្រះ អង្គជំណុំជម្រះសាលាដំបូងបានអញ្ជើញសហព្រះរាជអាជ្ញា “អោយចង្អុលបង្ហាញនូវមូលដ្ឋាននៃការអះអាងរបស់ខ្លួនដែលថា ឧក្រិដ្ឋកម្មជាតិមិនត្រូវបានរារាំងដោយអាជ្ញាយុកាលទាក់ទងនឹងជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២” ហើយបានអនុញ្ញាតអោយក្រុមមេធាវីការពារក្តីនានា ឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋាននេះ។ *សូមមើល* សេចក្តីបង្គាប់ដល់ភាគីទាក់ទងនឹងអនុញ្ញត្រកម្ម និងបញ្ហាទាំងទងនានា ចុះថ្ងៃទី ៥ មេសា ២០១១ ឯកសារលេខ E51/7 ទំព័រ២។ សហព្រះរាជអាជ្ញាមិនបានបកស្រាយបញ្ហាភ័ន្តច្រលំជាក់លាក់មួយចំនួនរបស់អង្គបុរេជំនុំជម្រះឡើយ ដូច្នេះហើយ មេធាវីការពារក្តីមិនអាចមានលទ្ធភាពដើម្បីបកស្រាយលើបញ្ហាទាំងនេះនៅក្នុងការឆ្លើយតបនេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់មធាវីការពារក្តី អៀង សារី សុំការអនុញ្ញាតដើម្បីដាក់សេចក្តីសន្និដ្ឋានបន្ថែម ដោយបញ្ជាក់ថា “អង្គជំនុំជម្រះ កត់សម្គាល់នូវសំណើរបស់មេធាវីការពារក្តី អៀង សារី សុំដាក់សេចក្តីសន្និដ្ឋានបន្ថែមទៅលើអញ្ញត្រកម្មរបស់ខ្លួនចំពោះយុត្តាធិការរបស់ អវតក ទៅលើឧក្រិដ្ឋកម្មជាតិ (E94)។ អង្គជំនុំជម្រះ សូមណែនាំថា អង្គជំនុំជម្រះមិនតម្រូវអោយមានការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរបន្ថែមទៀតទៅលើបញ្ហាទាំងនេះទៀតឡើយ។ ប៉ុន្តែ មេធាវីការពារក្តី អៀង សារី អាចបកស្រាយបញ្ហាទាំងនេះនៅក្នុងអំណះអំណាងផ្ទាល់មាត់ នៅក្នុងសវនាការបឋមបានបើសិនជាខ្លួនចង់លើកឡើង”។ របៀបវារៈសម្រាប់សវនាការបឋម ចុះថ្ងៃទី ១៤ កុម្ភៈ ២០១១ ឯកសារ E86/1 កថាខណ្ឌ ៥។ មេធាវីការពារក្តី អៀង សារី មានបំណងបង្ហាញនូវការវិភាគដ៏ស៊ីជម្រៅមួយទៅលើបញ្ហាទាំងនេះនៅក្នុងសវនាការបឋម។

[៥] សេចក្តីសន្និដ្ឋានរបស់ ក.ស.៣ កថាខណ្ឌ ២១។

[៦] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣។

ខ. "សង្គ្រាមស៊ីវិលជាបន្តបន្ទាប់បានធ្វើឱ្យស្ទើរតែមិនអាចកាត់សេចក្តីលើជនជាប់ចោទបាន រហូតទាល់តែពួកគេបានចុះចូលជាមួយនឹងរដ្ឋាភិបាលកម្ពុជានៅក្នុងឆ្នាំ ១៩៩៦ និង ១៩៩៨"[៧]។

គ. "ជនជាប់ចោទត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះលក្ខខណ្ឌនានា ដែលបានរារាំងដល់ការកាត់សេចក្តីលើពួកគេក្នុងអំឡុងរយៈពេលនោះ"[៨]។

២. មេធាវីការពារក្តីនឹងឆ្លើយតបទៅនឹងទឡ្ហីករណ៍នីមួយៗទាំងនេះម្តងមួយៗ។

## II. ទឡ្ហីករណ៍

៣. អាជ្ញាយុកាលសម្រាប់បទល្មើសជាតិនៃមាត្រា ៣ថ្មី បានផុតកំណត់យ៉ាងយូរបំផុតក្នុងឆ្នាំ១៩៨៩[៩] ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងក្នុងឆ្នាំ ១៩៧៥-១៩៧៩។ ក.ស.ព អះអាងថា ដោយផ្អែកទៅលើគោលការណ៍ស្តីពី *contra non valentem agere nulla currit praescriptio (contra non valentem)* ("អាជ្ញាយុកាលមិនអាចប្រើប្រឆាំងទៅនឹងជនដែលមិនបានប្រព្រឹត្តទេ")[១០] "រដ្ឋទាំងឡាយបានយល់ឃើញជាសាកលថា លក្ខខណ្ឌនានា ដែលធ្វើឱ្យស្ទើរតែមិនអាចប្រតិបត្តិបានក្នុងចំណាត់ការតាមផ្លូវច្បាប់ ដូចជាស្ថានភាពដែលមានសង្គ្រាមជាដើម បានបង្អាក់ដំណើរការតុលាការ ឬការប្រព្រឹត្តិរបស់ចុងចោទ បានផ្អាកអាជ្ញាយុកាល"[១១]។ គោលការណ៍ដែលយកមកធ្វើជាសំអាងនេះ មិនមែនជាគោលការណ៍ស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា

---

[៧] ដូចដើងទំព័រខាងលើ។

[៨] ដូចដើងទំព័រខាងលើ។

[៩] សូមមើល ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ១០៩។ កត់សម្គាល់ថា មាត្រា៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក "ពន្យារ" អាជ្ញាយុកាលជាថ្មីរមាន ៣០ឆ្នាំ ទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីអាជ្ញាយុកាលបានផុតកំណត់ ពុំមានរយៈពេលអាជ្ញាយុកាលពន្យារដែលមានសុពលភាពឡើយ។

[១០] គោលការណ៍នេះត្រូវបានបកប្រែថា "អាជ្ញាយុកាលមិនអាចប្រើប្រឆាំងនឹងជនដែលមិនអាចប្រព្រឹត្តបាន (ឬធ្វើការចោទប្រកាន់បាន) BLACK'S LAW DICTIONARY 1626 (7th ed. 1999)។

[១១] សេចក្តីសន្និដ្ឋានរបស់ ក.ស.ព កថាខណ្ឌ ៣។

និងមិនមានចែងនៅក្នុងច្បាប់កម្ពុជាជាធរមានឡើយ។ ក.ស.ព អះអាងថា *contra non valentem* គឺជា "គោលការណ៍ច្បាប់ធម្មជាតិ" ដែលផ្អែកទៅលើរឿងក្តីមួយរបស់សហរដ្ឋអាមេរិក ("USA") ពីឆ្នាំ១៨២២ ដែលពាក់ព័ន្ធនឹងការទិញទាសករ[១២]។ គោលការណ៍ច្បាប់ធម្មជាតិដែលត្រូវបានគាំទ្រ ដោយទស្សនវិទូផ្នែកច្បាប់ និងនយោបាយ មិនមែនជាអ្វីសម្រាប់ជំនួសច្បាប់ជាវិជ្ជមាន ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិដែលត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវបានឡើយ ជាពិសេសនៅពេលដែលគោលការណ៍ច្បាប់ធម្មជាតិ ទោះបីជាល្អឥតខ្ចោះក៏ដោយ មានលក្ខណៈខុសពីគោលនយោបាយសាធារណៈ ដែលជាមូលដ្ឋាននៃទ្រឹស្តីនៃអាជ្ញាយុកាលដែលលំអៀងទៅរកសច្ចភាព[១៣]។

៤. *Contra non valentem* មិនត្រូវបានយកមកអនុវត្តញឹកញាប់ឡើយ ហើយលក្ខខណ្ឌតម្រូវរបស់វាខ្ពស់ណាស់។ នៅក្នុងប្រទេសបារាំង "តុលាការតែងតែចាត់ទុកភាសិតនេះថាជាករណីលើកលែងមួយ ហើយយកវាមកអនុវត្តយ៉ាងប្រុងប្រយ័ត្នបំផុត ដែលអាចត្រូវបានគេឃើញមាននៅក្នុងលក្ខខណ្ឌនានាដែលភាសិតនេះត្រូវបានយកមកអនុវត្ត...។ ភាពមិនអាចប្រតិបត្តិបានត្រូវតែ<u>ជាក់លាក់ដាច់ខាត</u> ឬម្យ៉ាងវិញទៀត ប្រភពនៃភាពមិនអាចប្រតិបត្តិបាននេះត្រូវតែប្រហាក់

---

[១២] ដូចជើងទំព័រខាងលើ កំណត់សម្គាល់ ៦១ ដកស្រង់រឿងក្តី *Morgan ទល់នឹង* Robinson, 12 Mart. (0. S.) 77, 13 Am. Dec. 366។

[១៣] កត់សម្គាល់ថា នៅក្នុងរឿងក្តី *Hatch ទល់នឹង Gilmore* ដែល ក.ស.ព បានដកស្រង់នោះ ត្រូវបានយល់ឃើញថា "គោលការណ៍នេះ (*អាជ្ញាយុកាលមិនអាចប្រើប្រឆាំងនឹងជនដែលមិនអាចប្រព្រឹត្តបាន*) ដែលត្រូវបានលើកសរសើរដោយអ្នកច្បាប់មួយចំនួន ត្រូវបានរិះគន់ពីបុគ្គលដទៃទៀត ថាជាការបើកទ្វារឲ្យមានការរំលោភបំពាន ដោយសារតែវាមានភាពមិនច្បាស់លាស់ និងមានលក្ខណៈទូទៅ"។ រឿងក្តី *Hatch ទល់នឹង Gilmore,* 3 La. Ann. 508, 509 (1848)។ កត់សម្គាល់ផងដែរថា ក.ស.ព ផ្អែកទៅលើរឿងក្តីនេះ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួនថា យុត្តិសាស្ត្របារាំងបានអនុវត្តគោលការណ៍នេះ។ រឿងក្តីនេះគឺជារឿងក្តីឆ្នាំ១៨៤៨ នៅរដ្ឋ Louisiana ក្នុងសហរដ្ឋអាមេរិក។ វាជារឿងក្តីរដ្ឋប្បវេណី មិនមែនជារឿងក្តីព្រហ្មទណ្ឌទេ។ លើសពីនេះទៀត វាមិនបានរកឃើញថា គោលការណ៍នេះអាចអនុវត្តបានឡើយ ដោយផ្អែកលើអង្គហេតុនៃរឿងក្តី ថែមទាំងបានបញ្ជាក់ថា "តាមទស្សនៈដែលយើងបានសំដែងចេញ យើងសន្មតសម្រាប់គោលបំណងនៃទឡ្ហីករណ៍ ថា គោលការណ៍ *Contra non valentem, &c.* នឹងអនុវត្តចំពោះរឿងក្តី នៅចំពោះមុខយើង...។ ទោះបីយ៉ាងណាក៏ដោយ យើងមិនចង់ឲ្យគេពិចារណាថាជាការសំដែងនូវទស្សនៈលើចំណុចនោះ ឡើយ ពីព្រោះនៅពេលនេះ វាមិនចាំបាច់ធ្វើដូច្នេះឡើយ"។ ដូចខាងលើ ត្រង់ចំណុច ៥១០។

ប្រហែលទៅនឹង *ប្រធានសក្តិ*[១៤]។ ស្ថានភាពសង្គ្រាម នឹងមិនធ្វើឱ្យរដ្ឋនានា យល់ឃើញ "ជាសាកល" ថា អាជ្ញាយុកាលត្រូវបានព្យួរឡើយ[១៥]។ ដូចដែល ក.ស.ព បានចង្អុលបង្ហាញ[១៦]

---

[១៤] រឿងក្តី Benjamin West Janke & François-Xavier Licari, Contra Non Valentem *in France and Louisiana: Revealing the Parenthood, Breaking a Myth*, 71 LA. LAW REV. 503, 515 (2011) ("Janke & Licari") (សេចក្តីបញ្ជាក់បន្ថែម)។

[១៥] ដូចដែលចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងពន្យល់យ៉ាងដូច្នេះថា "ការអនុវត្តរបស់រដ្ឋមួយចំនួន បានបញ្ជាក់ថា ថិរវេលានៃអាជ្ញាយុកាលអាចនឹងមិនរាប់នៅក្នុងអំឡុងពេលដែលប្រព័ន្ធតុលាការ មិនមានសមត្ថភាព ដោយសារតែសង្គ្រាម ឬនៅពេលបទឧក្រិដ្ឋដែលចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងដោយមន្ត្រីរបស់រដ្ឋនោះខ្លួនឯង។ ប៉ុន្តែការអនុវត្តភាគច្រើនរបស់រដ្ឋទាំងនោះ កើតចេញមកពីច្បាប់ជាតិដែលរៀបចំឡើងដើម្បីអាច ធ្វើការចោទប្រកាន់ចំពោះបទល្មើសនានា ដែលថិរវេលាអាជ្ញាយុកាលនឹងត្រូវផុតរលត់"។ *រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការការពារក្តី ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E187 ("សំណុំរឿងលេខ០០១ សេចក្តីសម្រេចស្តីពីបទល្មើសជាតិ"), កថាខណ្ឌ២៩។ នៅប្រទេស ហុងគ្រី គេបានយល់ឃើញថា វាជារឿងមិនស្របនឹងរដ្ឋធម្មនុញ្ញក្នុងការពន្យារពេលដែលអនុវត្តប្រតិសកម្មទៅលើអាជ្ញាយុកាលដែលបានកន្លងផុតហើយនោះ។ សូមមើល RUTH A KOK អាជ្ញាយុកាលនៃបទល្មើសនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (RUTH A. KOK, STATUTORY LIMITATIONS IN INTERNATIONAL CRIMINAL LAW 301-02 (2007))។ នៅប្រទេសកូរ៉េខាងត្បូង ចៅក្រម ៥នាក់ក្នុងចំណោម ៩នាក់ នៃតុលាការធម្មនុញ្ញរបស់ប្រទេសកូរ៉េខាងត្បូង បានយល់ឃើញថា ច្បាប់មួយដែលផ្អាកច្បាប់អាជ្ញាយុកាល "នៅក្នុងអំឡុងពេល ដែលមានកើតឡើងនូវមូលហេតុដែលរារាំងប្រជាជាតិមួយមិនអោយអនុវត្តនូវអំណាចចោទប្រកាន់ផ្តន្ទាទោសរបស់ខ្លួន" គឺមិនស្របនឹងរដ្ឋធម្មនុញ្ញ បើសិនយកមកអនុវត្តដើម្បីចោទប្រកាន់ផ្តន្ទាទោសប្រឆាំងនឹងបុគ្គលទាំងឡាយ ដែលអាជ្ញាយុកាលអនុវត្តទៅលើបុគ្គលនោះបានកន្លងផុតទៅហើយ។ *សូមមើល* James M. West *Martial Lawlessness: The Legal Aftermath of Kwangju*, 6 PAC. RIM L. & POL'Y 85, 121-24 (1997) ។ *សូមមើលផងដែរ* Janke & Licari ត្រង់ទំព័រ ៥២៦ (ដែលពិភាក្សាច្បាប់បារាំង)។ "អត្ថិភាពនៃសង្គ្រាម ឬជំងឺតែប៉ុណ្ណោះ មិនអាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីប្រើប្រាស់គោលការណ៍នេះបានទេ ៖ ភាពមិនអាចប្រតិបត្តិបានត្រូវតែជាក់លាក់ដាច់ខាត ឧទាហរណ៍ ដោយសារតែតុលាការបិទទ្វារ ឬមិនអាចចូលទៅបាន។ ប្រការនេះតម្រូវឱ្យ មានការវាយតម្លៃតាមករណីនីមួយៗ ដែលហួសពីការគ្រប់គ្រងរបស់តុលាការកំពូល (Cour de cassation) ដោយសារតែការស៊ើបអង្កេតពុំមែនត្រឹមតែជាការស៊ើបអង្កេតផ្នែកច្បាប់ឡើយ។ ការអនុម័តរបស់តុលាការកំពូលនូវ ទស្សនទានដ៏តឹងរ៉ឹងអំពី *ប្រធានសក្តិ* ដែលត្រូវបានលើកទឹកចិត្ត និងយល់ស្របដោយអ្នកនិពន្ធអត្ថបទនេះ គឺស្របគ្នាជាមួយនឹងការសរសេររបស់អ្នកច្បាប់ដ៏កំពូលនៅ Orléans គឺលោក Robert-Joseph Pothier ដែលការសរសេររបស់គាត់ ស្តីពីអាជ្ញាយុកាល ចុះកាលបរិច្ឆេទមុនក្រមរដ្ឋប្បវេណីបារាំង (*Code Napoléon*) ហើយនៅតែពាក់ព័ន្ធសូម្បីតែរហូតមក ដល់បច្ចុប្បន្ននេះ"។ (សេចក្តីបញ្ជាក់បន្ថែម)

[១៦] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

និងដូចដែលចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីមុនៗ វាត្រូវតែ "មិនអាច" ប្រតិបត្តិបានក្នុងចំណាត់ការតាមផ្លូវច្បាប់ មុនពេលអាជ្ញាយុកាលនឹងត្រូវបានព្យួរ[១៧]។ វាអាចប្រតិបត្តិបានក្នុងចំណាត់ការតាមផ្លូវច្បាប់ក្នុងអំឡុងរយៈពេលឆ្នាំ១៩៧៩-១៩៨៩ ដូចដែលបានបង្ហាញខាងក្រោមនេះ។ អាជ្ញាយុកាលមិនអាចត្រូវបានពិចារណាថាបានព្យួរឡើយក្នុងអំឡុងរយៈពេលនោះ។

## ក. ប្រព័ន្ធតុលាការបានដំណើរការក្នុងអំឡុងរយៈកាលទាំងមូលបន្ទាប់ពីបទល្មើសត្រូវបានចោទប្រកាន់ថាបានកើតឡើង

៥. ក.ស.ព អះអាងថា "កាលណាមានវត្តមាននៃកត្តាផ្សេងៗដែលមកបង្អាក់ដល់ 'ការគ្រប់គ្រងដ៏ត្រឹមត្រូវលើវិស័យយុត្តិធម៌' លំហូរនៃអាជ្ញាយុកាលគឺត្រូវបានព្យួរហើយ"[១៨]។ ក.ស.ព ភ័ន្តច្រឡំអំពីប្រព័ន្ធតុលាការដែលដំណើរការ ជាមួយនឹងប្រព័ន្ធតុលាការដ៏ល្អឥតខ្ចោះ។ ប្រព័ន្ធតុលាការ<u>ត្រូវតែមិនដំណើរការ</u> ដើម្បីឲ្យអាជ្ញាយុកាលត្រូវបានព្យួរ[១៩] ហើយសូម្បីតែនៅក្នុងស្ថានភាពដូច្នេះ ក៏ដោយតុលាការមិនតែងតែយល់ឃើញថា ការព្យួរអាជ្ញាយុកាលជាការត្រឹមត្រូវឡើយ[២០]។ នៅ អ.វ.ត.ក បច្ចុប្បន្ននេះ មានការចោទប្រកាន់ថា ការគ្រប់គ្រងដ៏ត្រឹមត្រូវលើវិស័យយុត្តិធម៌ ត្រូវបានរារាំង

---

[១៧] សំណុំរឿងលេខ០០១ សេចក្ដីសម្រេចស្ដីពីបទល្មើសជាតិ កថាខណ្ឌ ១៦, ៣១។

[១៨] សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣។

[១៩] យោងតាមចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង "នៅពេលដែលស្ថានភាពជាសត្យានុម័តមួយបង្ហាញថា ការស៊ើបអង្កេតមិនអាចធ្វើទៅបានចំពោះជននោះ ចិរវេលានៃអាជ្ញាយុកាល <u>មិនអាចអនុវត្តបានទេ</u>ក្នុងករណីនេះ។ បន្ថែមលើនេះទៀត ការអនុវត្តជាក់ស្ដែងនៃប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសដទៃបង្ហាញថា ដំណើរការនៃប្រព័ន្ធតុលាការគឺជាបុរេលក្ខខណ្ឌសម្រាប់ការចាប់ផ្ដើមរាប់ចិរវេលានៃអាជ្ញាយុកាល"។ សំណុំរឿងលេខ០០១ សេចក្ដីសម្រេចស្ដីពីបទល្មើសជាតិ កថាខណ្ឌ១៦-១៧ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* Janke & Licari, ត្រង់លេខ ៥១៥ ។

[២០] ដូចដែលចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ "ការអនុវត្តរបស់រដ្ឋ<u>មួយចំនួន</u> បានបញ្ជាក់ថា ចិរវេលានៃអាជ្ញាយុកាលអាចនឹងមិនរាប់នៅក្នុងអំឡុងពេលដែលប្រព័ន្ធតុលាការ មិនមានសមត្ថភាព ដោយសារតែសង្គ្រាម ឬនៅពេលបទឧក្រិដ្ឋដែលចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងដោយមន្ត្រី របស់រដ្ឋនោះខ្លួនឯង។ ប៉ុន្តែការអនុវត្តភាគច្រើនរបស់រដ្ឋទាំងនោះកើតចេញមកពីច្បាប់ជាតិដែលរៀបចំឡើងដើម្បីអាច ធ្វើការចោទប្រកាន់ចំពោះបទល្មើសនានា ដែលចិរវេលាអាជ្ញាយុកាលនឹងត្រូវផុតរលត់"។ សំណុំរឿងលេខ០០១ សេចក្ដីសម្រេចស្ដីពីបទល្មើសជាតិ កថាខណ្ឌ២៩ (គូសបញ្ជាក់បន្ថែម)។

ដោយការចាត់ចែងកិច្ចស៊ើបអង្កេតទៅក្នុងសំណុំរឿង ០០៣ របស់ ក.ស.ច.ស[21]។ តាមពិត សង្គមសិទ្ធិមនុស្សអាស៊ីបានចេញសេចក្តីប្រកាស់ព័ត៌មានមួយដែលបញ្ជាក់ថា "ការវិវឌ្ឍន៍ នាពេលថ្មីៗនេះនៅ អ.វ.ត.ក ទាក់ទិននឹងសំណុំរឿង ០០៣ និង ០០៤ ធ្វើឲ្យយើងកាន់តែព្រួយបារម្ភថា ភាពអនាគតិ សុចរិតភាព និងឯករាជ្យភាពរបស់ចៅក្រម អ.វ.ត.ក កំពុងតែត្រូវបានធ្វើឱ្យមានស្លាកស្នាម"[២២]។ ទោះបីជាប្រការនេះអាចបង្ហាញអំពីបញ្ហាធ្ងន់ធ្ងររបស់ អ.វ.ត.ក និងចោទជាមន្ទិលអំពីគុណភាពនៃយុត្តិធម៌ ដែលនឹងកើតមាននៅពេលខាងមុខនេះយ៉ាងណាក៏ដោយ វាមិនបង្ហាញឲ្យឃើញថា អ.វ.ត.ក បានបញ្ឈប់ដំណើរការទាំងស្រុងនោះឡើយ។

៦. ក.ស.ព ដកស្រង់រឿងក្តីតែពីរប៉ុណ្ណោះដើម្បីគាំទ្រការអះអាងរបស់ខ្លួនថា "សូម្បីតែនៅក្នុងប្រទេស

---

[២១] សហព្រះរាជអាជ្ញាអន្តរជាតិ បានចេញនូវសេចក្តីប្រកាសពត៏មាននាពេលថ្មីៗនេះ ដែលក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ បានយល់ឃើញថា វាជាការចាំបាច់ដើម្បីរំលឹកដល់ កសចស ថា "សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចតាមវិធានផ្ទៃក្នុង ៥៥ និងតាមច្បាប់របស់ អវតក ក្នុងការបំពេញការស៊ើបសួររបស់ខ្លួនប្រកបដោយអនាគតិ និងបំពេញកិច្ចស៊ើបសួរដើម្បីឈានទៅរកការពិត"។ សេចក្តីប្រកាសពត៏មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (១៤ មិថុនា ២០១១)។

[២២] សេចក្តីប្រកាសព័ត៌មាន គណៈកម្មការសិទ្ធិមនុស្សអាស៊ី ប្រទេសកម្ពុជាៈ សង្គមស៊ីវិលបានបង្ហាញពី ការព្រួយបារម្ភទៅលើការវិវឌ្ឍន៍ថ្មីៗនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបានជម្រុញឱ្យសហគមធ្វើការបញ្ចេញមតិ (ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១)។ សូមមើលផងដែរ James O'Toole ចៅក្រមបដិសេធសំណើសុំក្នុងសំណុំរឿង ០០៣ កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១១។ "Anne Heindel ទីប្រឹក្សាច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា បាននិយាយថា ដោយមានសេចក្តីសម្រេចកាលពីម្សិលម៉ិញ ចៅក្រមទាំងឡាយ "បានព្យាយាមបញ្ចប់សំណុំរឿង ០០៣ តាមបច្ចេកទេសដែលពួកគាត់បានបង្កើតឡើងសម្រាប់គោលបំណងនេះ"។ Jared Ferrie, *Leaked Document Casts Doubt on Impartiality of Khmer Rouge Judges*, CHRISTIAN SCIENCE MONITOR ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១១ "មជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្សកម្ពុជា បានបញ្ចេញមតិថា "ការបង្ហាញឱ្យឃើញពីឯករាជ្យភាពនៅស្ថាប័ននេះ គឺមិនមានតាំងពីយូរមកហើយ"។ ចៅក្រមទាំងឡាយបានបដិសេធយ៉ាងខ្លាំងក្លាលើការទាមទារនេះនៅក្នុងសេចក្តីថ្លែងការណ៍ថ្ងៃទី ២៦ ខែ ឧសភា ដោយបានលើកឡើងថា "ពួកគាត់បានធ្វើការដោយឯករាជ្យដាច់ចេញពីការជ្រៀតជ្រែក ពីខាងក្រៅ ហើយនឹងបន្តតស៊ូនឹងការប៉ុនប៉ងទាំងនេះ ហើយតាំងចិត្តការពារឯករាជ្យភាពរបស់ខ្លួន ប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅ មិនថាការជ្រៀតជ្រែកនោះចេញមកពីប្រភពណាទេ"។ ទោះបី ជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍យ៉ាងយកចិត្តទុកដាក់របស់តុលាការ បានសង្កេតឃើញការលំបាកនានាដែលព្រះរាជអាជ្ញាបានជួបប្រទះ នៅក្នុងការនាំយកមេដឹកនាំខ្មែរក្រហមលើសពីប្រាំនាក់មកធ្វើការជំនុំជម្រះក្តី។ Ann Heindel ដែលជាទីប្រឹក្សាច្បាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើការស្រាវជ្រាវអំពីប្រវត្តិខ្មែរក្រហម បានលើកឡើងថា "រដ្ឋាភិបាលកម្ពុជាមិនចង់ឲ្យរឿងក្តី ទាំងនេះដំណើរការទៅមុខទេ ព្រះរាជអាជ្ញាកម្ពុជាបានទទួលសម្ពាធពីភាគីរដ្ឋាភិបាល រីឯសហគមន៍អន្តរជាតិមិនចង់ទទួលរងកំហុសនោះទេ"។

នានាដែលប្រព័ន្ធច្បាប់នៅកំពុងតែដំណើរការ តែកាលណាមានវត្តមាននៃកត្តាផ្សេងៗដែលមកបង្អាក់ដល់ 'ការគ្រប់គ្រងដ៏ត្រឹមត្រូវលើវិស័យយុត្តិធម៌' លំហូរនៃអាជ្ញាយុកាលគឺត្រូវបានព្យួរហើយ"[២៣]។ រឿងក្តីទាំងពីរគឺជារឿងក្តីរដ្ឋប្បវេណី ដែលយកមកជំនុំជម្រះនៅក្នុងសហរដ្ឋអាមេរិកក្រោមច្បាប់ការពារជនរងគ្រោះដោយសារអំពើទារុណកម្ម ("TVPA")។ មិនដូចជាបទប្បញ្ញត្តិពាក់ព័ន្ធរបស់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឡើយ ច្បាប់ការពារជនរងគ្រោះដោយសារអំពើទារុណកម្ម "ចែងអំពីអាជ្ញាយុកាលរយៈពេល ១០ឆ្នាំ ប៉ុន្តែស្នើយ៉ាងជាក់លាក់ឲ្យមានការពិចារណាអំពីគោលការណ៍នៃការព្យួរអាជ្ញាយុកាលដោយសមធម៌ទាំងអស់ នៅក្នុងការគិតអំពីរយៈពេលនេះដោយមានទស្សនៈសំដៅផ្តល់យុត្តិធម៌ទៅដល់សិទ្ធិរបស់ដើមចោទ"[២៤]។ នៅក្នុងរឿងក្តី *Arce ទល់នឹង Garcia* ដើមចោទបានប្តឹងចុងចោទនៅក្នុងតុលាការសហរដ្ឋអាមេរិកក្នុងខែ ឧសភា ឆ្នាំ ១៩៩៩ ដោយចោទប្រកាន់ថា ពួកគាត់ត្រូវបានកងយោធានៅក្នុងប្រទេសអែលសាល់វ៉ាឌ័រ ធ្វើទារុណកម្មក្នុងអំឡុងយុទ្ធនាការមួយនៃការរំលោភសិទ្ធិមនុស្សពីសំណាក់កងយោធាអែលសាល់វ៉ាឌ័រ ចាប់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៣។ តុលាការប្រចាំរដ្ឋក្នុងសហរដ្ឋអាមេរិកយល់ឃើញថា អាជ្ញាយុកាលត្រូវបានព្យួរ។ ការសម្រេចបែបនេះត្រូវបានតម្កល់ទុកដោយសាលាឧទ្ធរណ៍ ពីព្រោះ "រហូតដល់បញ្ចប់សង្គ្រាម ស៊ីវិលក្នុងឆ្នាំ១៩៩២ កងកម្លាំងយោធាបានប្រើអំណាចពិសេសដើម្បីរារាំងដល់ការខិតខំប្រឹងប្រែងណាមួយក្នុងការសងជំងឺចិត្តចំពោះការរំលោភសិទ្ធិមនុស្សដែលកងយោធាបានប្រព្រឹត្ត។ <u>ភស្តុតាង អំពីការរំលោភទាំងនោះត្រូវបានគេបំបិទចោល</u>។ អ្នកដែលអាចក្លាយជាសាក្សីត្រូវបានគេបំភិតបំភ័យ និងទំនងជាត្រូវគេធ្វើទារុណកម្មប្រសិនបើពួកគេបង្ហាញខ្លួន។ ដើមចោទមានហេតុផលសមស្របក្នុងការខ្លាចថាសមាជិកគ្រួសារ និងមិត្តភ័ក្ររបស់ពួកគេក្នុងប្រទេសអែលសាវ៉ាឌ័រ នឹងទទួលរងនូវការសងសឹកដ៏សាហាវ និងទទួលរងនូវអំពើឃោរឃៅយង់ឃ្នងដូចដែលដើមចោទបានទទួលរងដែរ..។ភស្តុតាងបង្ហាញថាប្រព័ន្ធតុលាការទុនខ្សោយខ្លាំងពេកមិនប៊ានប្រឆាំងនឹងរបបនោះ"[២៥]។

---

[២៣] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣។

[២៤] រឿងក្តី *Arce ទល់នឹង Garcia*, 434 F.3d 1254, 1262 (11th Cir. Fla. 2006)។

[២៥] ដូចជើងទំព័រខាងលើ ត្រង់ចំណុច ១២៦៣-៦៤ (សេចក្តីបញ្ជាក់បន្ថែម)។ តុលាការបានបញ្ជាក់ផងដែរថា "អាជ្ញាយុកាលគឺជាគោលបំណងដ៏សំខាន់នៅក្នុងប្រព័ន្ធច្បាប់របស់យើង ហើយគួរតែត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងនៅគ្រប់កាលៈទេសៈ លើកលែងតែកាលៈទេសៈដែលធ្ងន់ធ្ងរបំផុត"។ ដូចជើងទំព័រខាងលើ ត្រង់ចំណុច ១២៦៥។

នៅក្នុងរឿងក្តី *Cabello ទល់នឹង Fernandez-Larios* ដែលជារឿងក្តីមួយពាក់ព័ន្ធនឹងអំពើមនុស្សឃាតដែលត្រូវបានចោទប្រកាន់នៅក្នុងប្រទេសស៊ីលីក្នុងឆ្នាំ ១៩៧៣ បន្ទាប់ពីមានរដ្ឋប្រហារមួយ តុលាការយល់ឃើញថា "ការលាក់កំបាំងអំពីព្រឹត្តការណ៍ជុំវិញការស្លាប់របស់លោក Cabello ធ្វើឱ្យវាស្ទើរតែមិនអាចឱ្យអ្នកនៅរស់រានមានជីវិតត្រកូល Cabello រកឃើញនូវអំពើអយុត្តិធម៌ដែលត្រូវបានប្រព្រឹត្តលើលោក Cabello។ ជាលទ្ធផលនៃការលាក់កំបាំងដោយចេតនារបស់អាជ្ញាធរស៊ីលី ការព្យួរអាជ្ញាយុកាលដោយសមធម៌ គឺមានលក្ខណៈសមស្របនៅក្នុងរឿងក្តីនេះ"[២៦]។ ពុំមានរឿងក្តីណាមួយផ្តល់នូវកម្លាំងគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការអះអាងរបស់ ក.ស.ព ឡើយ។

៧. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានទំនោរចង់អនុវត្តតាមយុត្តិសាស្ត្ររដ្ឋប្បវេណីជាតិរបស់សហរដ្ឋអាមេរិកយ៉ាងណាក៏ដោយ រឿងក្តីទាំងពីរមានលក្ខណៈខុសគ្នាយ៉ាងច្បាស់ក្រឡែតពីរឿងក្តីនេះ។ ក.ស.ព ពុំបានបង្ហាញភស្តុតាងថា ប្រព័ន្ធតុលាការកម្ពុជាមានភាពទុនខ្សោយខ្លាំងមិនអាចប្រឆាំងនឹងជនជាប់ចោទ ឬក៏បង្ហាញថា រដ្ឋាភិបាល ឬជនជាប់ចោទបានជាប់ពាក់ព័ន្ធនៅក្នុងការបំបិទចោលភស្តុតាងឡើយ។ ដូចដែលចៅក្រមអន្តរជាតិរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១ បានចង្អុលបង្ហាញ ៖

> ទោះបីជាសង្គ្រាមស៊ីវិល និងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ខ្មែរក្រហមទៅលើតំបន់មួយចំនួនក្នុងប្រទេស ដែលអាចបង្ហាញនូវឧបសគ្គយ៉ាងពិតប្រាកដនៅក្នុងការផ្តួចផ្តើមការចោទប្រកាន់ ឬការស៊ើបសួររបស់តុលាការក៏ដោយ ក៏ចៅក្រមអន្តរជាតិសន្និដ្ឋានថា ការស៊ើបសួរ ឬការចោទប្រកាន់មិនបានបង្អាក់គ្រប់កន្លែងនៅក្នុងប្រទេសនោះទេ។ចៅក្រមអន្តរជាតិយល់ឃើញថា សម្ភារៈឯកសារជាច្រើនដែលត្រូវបានរកឃើញនៅមន្ទីរ ស២១ ត្រូវបានមន្ទីរ ស២១ បានប្រមូល និងរក្សាទុកភ្លាមៗក្រោយពេលដែល... នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ និងក្រោយមកត្រូវបានប្រមូលនិងរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកស្រាវជ្រាវ និងអ្នកនិពន្ធ បានប្រើប្រាស់សម្ភារៈឯកសារ ទាំងនោះចាប់ តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០ ហើយអ្នកជំនាញ David CHANDLER ក៏បានផ្តល់ សក្ខីកម្មដោយផ្អែកលើសម្ភារៈឯកសារទាំងនេះដែរ។ ហេតុដូច្នេះ សម្ភារៈឯកសារទាំងនេះអាច យកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការស៊ើបអង្កេត

---

[២៦] រឿងក្តី *Cabello ទល់នឹង Fernandez-Larios*, 402 F.3d 1148, 1155 (11th Cir. Fla. 2005) (សេចក្តីបញ្ជាក់បន្ថែម)។

និងជំនុំជម្រះក្នុងអំឡុងពេលនោះ[២៧]។

ចៅក្រមអន្តរជាតិនៃជំនុំជម្រះសាលាដំបូង ក៏បានយល់ឃើញផងដែរថា៖

> "មានភស្តុតាងដើម្បីចង្អុលបង្ហាញថា ចាប់តាំងពីឆ្នាំ ១៩៧៩ មក ច្បាប់ និងក្រឹត្យនានាត្រូវបានអនុវត្តជាបន្តបន្ទាប់។ ជាឧទាហរណ៍ នៅក្នុងចន្លោះឆ្នាំ ១៩៨០ និង ១៩៨២ ក្រឹត្យនានាត្រូវបានចេញទាក់ទងនឹងការចាត់តាំងអង្គការតុលាការ និងនៅក្នុងឆ្នាំ ១៩៨៥ និង ១៩៨៧ បានចេញទាក់ទងនឹងការបង្កើតតុលាការកំពូល។ ក្រឹត្យជាក់លាក់មួយទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌជាតិក៏ត្រូវបានចេញដោយក្រឹត្យនៅក្នុងឆ្នាំ ១៩៨០ ដែលមានប្រសិទ្ធិភាពអនុវត្តប្រតិសកម្មគិតត្រឹមថ្ងៃ ៧ មករា ១៩៧៩ដែរ"[28]។

ដោយសារតែមន្ទីរ សង២១ ជាកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ដែលត្រូវបានយកមកសំអាងនៅក្នុងសំណុំរឿង ០០២ សេចក្តីបញ្ជាក់នេះអាចយកមកអនុវត្តចំពោះសំណុំរឿងនេះផងដែរ។ ភស្តុតាងជាច្រើនក៏ត្រូវបានប្រមូលផងដែរសម្រាប់ការជំនុំជម្រះក្តីឆ្នាំ១៩៧៩ លើ ប៉ុល ពត និង លោក អៀង សារី។ បច្ចុប្បន្ននេះ សម្ភារៈឯកសារនេះបង្កើតបានជាផ្នែកនៃសំណុំរឿង ០០២[២៩]។

៨. ក.ស.ព អះអាងថា "ជនជាប់ចោទត្រូវតែមានសិទ្ធិ និងធនធានដែលមានស្រាប់ដើម្បីបង្កើតឱ្យបាននូវការការពារមួយដ៏គ្រប់គ្រាន់ដោយរួមទាំងការដែលអាចរកបាននូវមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួនថែមទៀតផង។ បើមិនបានត្រូវទៅតាមលក្ខខណ្ឌតម្រូវអប្បបរមាបែបនេះទេ គេមិនអាចពិចារណាលើស្ថាប័នមួយថាជា តុលាការមួយដែលដំណើរការបានដោយមានលទ្ធភាពធ្វើការសម្រេចសេចក្តីលើបញ្ហាអ្វីមួយបាននោះទេ ហើយអលទ្ធភាពជាក់ស្តែងក្នុងការនាំយកនូវករណីដែលមានអត្ថិភាពមួយអនុញ្ញាតឱ្យមានការព្យួរអាជ្ញាយុកាល"[៣០]។ ក្តីបារម្ភរបស់ ក.ស.ព ចំពោះ

---

[២៧] សំណុំរឿងលេខ០០១ សេចក្តីសម្រេចស្តីពីបទល្មើសជាតិ កថាខណ្ឌ ៣៣។

[២៨] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣២។

[២៩] សូមមើល C22/I/32.34, GENOCIDE IN CAMBODIA: DOCUMENTS FROM THE TRIAL OF POL POT AND IENG SARY (Howard J. De Nike, John Quigley, & Kenneth J. Robinson eds., University of Pennsylvania Press, 2000)។

[៣០] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤។

សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌[៣១] គឺគួរឱ្យសរសើរ ប៉ុន្តែនេះមិនមែនជាលក្ខខណ្ឌវិនិច្ឆ័យដ៏សមស្របក្នុងការកំណត់ថាតើ អាជ្ញាយុកាលអាចត្រូវបានព្យួរ ឬយ៉ាងណាឡើយ។ លក្ខខណ្ឌវិនិច្ឆ័យដ៏សមស្រប គឺថាតើវាអាចមានលទ្ធភាព ក្នុងការចោទប្រកាន់ជនជាប់ចោទនៅក្នុងរយៈកាលមុនការផុតកំណត់អាជ្ញាយុកាលដែរឬទេ។ សូម្បីតែបច្ចុប្បន្ននេះ មានការព្រួយបារម្ភថា ការជំនុំជម្រះក្តីក្នុងប្រទេសកម្ពុជាអាចមិនមានយុត្តិធម៌។ ដូចដែលចៅក្រមជំនុំជម្រះ និល ណុន បានបញ្ជាក់នៅក្នុងបទសម្ភាសន៍ថ្មីៗនេះថា "*យើងក៏មានបញ្ហាដែរ ពីព្រោះចៅក្រមមិនមានឯករាជ្យឡើយនៅក្នុងប្រទេសកម្ពុជា [រដ្ឋាភិបាល] គំរាម និងដាក់សម្ពាធលើចៅក្រម ចៅក្រមទទួលលុយ ដូច្នេះទាំងអស់នេះ មិនល្អណាស់ណាទេ*"[៣២]។ ប្រការនេះមិនបង្ហាញថា ប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាមិនដំណើរការ ដែលវាមិនអាចអនុវត្តនូវការចោទប្រកាន់បាននោះឡើយ។ វាគ្រាន់តែគូសបញ្ជាក់នូវភាពទុនខ្សោយជាទូទៅ និងជាប្រព័ន្ធនៅក្នុងប្រព័ន្ធតុលាការកម្ពុជាប៉ុណ្ណោះ រាប់បញ្ចូលទាំង អ.វ.ត.កផង។

៩. ក.ស.ព អះអាងថា "ប្រព័ន្ធតុលាការដែលត្រូវបានបង្កើតឡើងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយដែលបានបន្តនៅមានអានុភាពរហូតដល់មានដំណើរការនៃការបង្កើតតុលាការពេញច្បាប់ជាថ្មីឡើងវិញក្នុងឆ្នាំ ១៩៩២ និងឆ្នាំ ១៩៩៣ គឺយកគំរូតាមប្រព័ន្ធតុលាការសង្គមនិយមសូវៀត ដែលធ្លាប់ត្រូវបានអនុវត្តនៅប្រទេសវៀតណាម"[៣៣]។ ក.ស.ព ថ្លែងដោយប្រយោលថា

---

[៣១] កត់សម្គាល់ថា នៅក្នុងជើងទំព័រ៧៧ នៃសេចក្តីសន្និដ្ឋានរបស់ ក.ស.ព, ក.ស.ព បានលើកឡើងថា "ការនិយាយអាក្រក់ជាសាធារណៈ អំពី "បនប៉ុល ពត អៀងសារី" ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា ធ្វើឱ្យការសន្មតថាគ្មានទោស (គោលការណ៍សច្ចធារណ៍និរទោស) ណាមួយ មិនអាចធ្វើទៅបានឡើយ ជាពិសេសនោះ គឺព្រោះដោយសារក្រឹត្យដែលបង្កើតតុលាការប្រជាជនបដិវត្តន៍នោះបានប្រកាសយ៉ាងច្បាស់អំពីពិរុទ្ធភាពរបស់ពួកគេ"។ មេធាវីការពារក្តីអះអាងថា ក.ស.ព មិនអាចយកសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌មកអនុវត្ត ដើម្បីរំលោភលើសិទ្ធិផ្សេងៗទៀតរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ ដូចជា សិទ្ធិក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់។ លើសពីនេះទៀត ការនិយាយអាក្រក់ជាសាធារណៈបន្តរហូតមកដល់បច្ចុប្បន្ន ដែលធ្វើឱ្យមានការពិបាកដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការធានាថា ជនជាប់ចោទបានទទួលនូវសច្ចធារណ៍នៃនិរទោស។

[៣២] សូមមើល Alex Bates, *Transitional Justice in Cambodia: Analytical Report*, ATLAS PROJECT, October 2010, កថាខណ្ឌ ១៤៥។

[៣៣] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។

គំរូយុត្តិធម៌ តាមសង្គមនិយមសូវៀត អាចមិន"ពេញច្បាប់"។ ការថ្លែងដោយប្រយោលនេះ រិះគន់ចំពោះប្រព័ន្ធតុលាការទាំងនេះ។ ក.ស.ព ពុំបានផ្តល់នូវភស្តុតាងក្នុងការគាំទ្រដល់ការអះអាងរបស់ខ្លួនឡើយ ថា នៅក្នុងគំរូតាមសង្គមនិយមសូវៀតមានលក្ខណៈមិនពេញច្បាប់។ គួររំលឹកថា ចៅក្រមកម្ពុជាជាច្រើន រួមទាំងចៅក្រមនៅ អ.វ.ត.ក បានទទួលការបណ្តុះបណ្តាលនៅក្នុងប្រទេសវៀតណាម ឬនៅក្នុងប្រព័ន្ធតុលាការផ្សេងៗទៀតដែលទទួលឥទ្ធិពលពីសូវៀត និងបានចាប់ផ្តើម អាជីពផ្នែកច្បាប់របស់ពួកគាត់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរយៈកាលឆ្នាំ១៩៧៩-៩១[៣៤]។ ពិតណាស់ ប្រសិនបើប្រព័ន្ធតុលាការដែលត្រូវបានអនុម័តដោយប្រទេសកម្ពុជាក្រោយឆ្នាំ ១៩៧៩ មិនពេញច្បាប់ នោះនឹងមានការបង្ហាញហេតុផលថា ដំណើរការនីតិវិធីទាំងអស់រហូតដល់ឆ្នាំ១៩៩៣ដែល ក.ស.ព អះអាងថាប្រទេសកម្ពុជាបានចាប់ផ្តើមបង្កើតប្រព័ន្ធតុលាការពេញច្បាប់ឡើងវិញនៅពេលនោះ មិនមានលក្ខណៈពេញច្បាប់។ តាមការយល់ដឹងរបស់មេធាវីការពារក្តី នៅក្នុងប្រទេសវៀតណាម ពុំមានការព្យួរអាជ្ញាយុកាលដោយផ្អែកលើមូលដ្ឋានថា ដោយសារតែប្រព័ន្ធសង្គមនិយម ប្រទេសនេះពុំមានប្រព័ន្ធតុលាការដែលដំណើរការបាននោះទេ។ បញ្ហាថាតើប្រព័ន្ធតុលាការក្នុងប្រទេសវៀតណាមមានយុត្តិធម៌ និងអនាគតិ ឬថាតើការបណ្តុះបណ្តាលផ្នែកវិស័យតុលាការពីសំណាក់ប្រទេសវៀតណាមមានលក្ខណៈត្រឹមត្រូវ ឬយ៉ាងណានោះពុំមែនជាបញ្ហាចោទឡើយសម្រាប់សេចក្តីសន្និដ្ឋាននេះ។

១០. ក.ស.ព អះអាងថា "នៅក្នុងរយៈកាលឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៩១ ទាំងប្រព័ន្ធច្បាប់ស៊ីវិលបារាំង និងទាំងក្រម[នីតិវិធី]ព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនត្រូវបានយកមកអនុវត្តឡើយ។ ផ្ទុយទៅវិញ ក្រមព្រហ្មទណ្ឌដែលយកមកអនុវត្ត គឺមាននៅក្នុងក្រឹត្យច្បាប់ឆ្នាំ ១៩៨០ ដែលមានចំណងជើងថា "ច្បាប់ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍"[៣៥] ហើយថា ច្បាប់លម្អិតដែលអនុញ្ញាតឱ្យមានការកាត់

---

[៣៤] ឧទាហរណ៍ យោងតាមគេហទំព័រ អ.វ.ត.ក ចៅក្រមជំនុំជម្រះរបស់អង្គបុរេជំនុំជម្រះ ប្រាក់ គឹមសាន បានចាប់ផ្តើមបម្រើការងារជាព្រះរាជអាជ្ញារងនៅខេត្តកំពង់ចាមក្នុងឆ្នាំ ១៩៨៧ ហើយចៅក្រម ន័យ ថុល ជាប្រធានតុលាការយោធា ចាប់តាំងពីឆ្នាំ ១៩៨៧។ សូមមើលគេហទំព័ររបស់ អ.វ.ត.ក http://www.eccc.gov.kh/english/pre-trial_chamber.aspx។

[៣៥] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦។ កត់សម្គាល់ថា ក.ស.ព ថ្លែងថាច្បាប់នេះ "ត្រូវបានព្រាងឡើងដោយអ្នកដែលមិនមែនជាអ្នកច្បាប់មួយរូប ក្នុងរយៈពេលចំនួនមួយសប្តាហ៍" ទំនងជាដើម្បីគាំទ្រជំហររបស់ខ្លួនដែលថា ប្រព័ន្ធតុលាការមិនបានដំណើរការ។ នីតិកម្ម មិនតម្រូវឱ្យត្រូវធ្វើសេចក្តីព្រាងដោយអ្នកច្បាប់ឡើយ ហើយការពិតដែលថា អ្នកដែល

សេចក្តីប្រកបដោយប្រសិទ្ធភាពលើបទល្មើសមនុស្សឃាត ការធ្វើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញខាងសាសនា" ពុំមានអត្ថិភាពឡើយ[៣៦]។ ប្រការនេះមិនពិតឡើយ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅតែមានជាធរមាននៅក្នុងអំឡុងរយៈកាលដែលលើកឡើងនេះ ទោះបីជាយកឬមិនយកមកអនុវត្តក៏ដោយ។ ក្រមនេះមិនដែលត្រូវបានទុកជានិរាករណ៍ឡើយក្នុងអំឡុងរយៈកាលដែលលើកឡើងនេះ។ តាមពិត ឃើញថា ការកាត់សេចក្តីបានប្រព្រឹត្តឡើងក្នុងអំឡុងរយៈកាលនេះ ដែលអាចផ្អែកទៅលើច្បាប់នេះ។ ការកាត់សេចក្តីដែលបានប្រព្រឹត្តឡើង មិនទំនងជាផ្អែកទៅលើតែច្បាប់ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍ឡើយ។ ម្យ៉ាងវិញទៀត "ច្បាប់ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍" ដែលកសព យកមកសំអាងនោះមានពីរផ្នែក។ ចំណងជើងពេញនៃច្បាប់នៃគឺ "ច្បាប់ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍ និងបណ្តាទោសប្រព្រឹត្តបទល្មើសផ្សេងៗទៀត"។ ផ្នែកទីមួយនៃច្បាប់នេះគឺទាក់ទងនឹងបទល្មើសទាំងឡាយទាក់ទងនឹងការក្បត់បដិវត្ត។ ផ្នែកទីពីរ ពាក់ព័ន្ធជាខ្លាំងទៅនឹងបញ្ហានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គ្របដណ្តប់ទៅលើបទល្មើសសាមញ្ញនានារួមមានឃាតកម្ម រំលោភសេពសន្ថវៈ ការបង្ករបួសស្នាម និងបទល្មើសប្រឆាំងទ្រព្យសម្បត្តិ[៣៧]។ ក្រុមមេធាវីការពារក្តី អៀង សារី បានចុះទៅសាលាដំបូងរាជធានីភ្នំពេញ ហើយគេបានជូនដំណឹងដោយផ្ទាល់មាត់ថា មានសាលក្រមមួយចំនួននៅក្នុងអំឡុងពេលពីឆ្នាំ ១៩៧៩ ដល់ ១៩៩១ ឧទាហរណ៍ ដូចជា ករណីឃាតកម្មជាអាទិ៍ ប៉ុន្តែការព្យាយាមដើម្បីទទួលបានសំណៅចម្លងនៃសាលក្រម មិនទទួលបានជោគជ័យឡើយគិតមកដល់ថ្ងៃនេះ[38]។ ដោយហេតុថាការពិនិត្យ ទៅលើ

---

មិនមែនជាអ្នកច្បាប់មួយរូបបានធ្វើសេចក្តីព្រាងផ្នែកពិសេសនៃច្បាប់នេះ មិនអាចពិចារណាថាជាភ័ស្តុតាងដែលថា ប្រព័ន្ធតុលាការមិនដំណើរការនោះឡើយ។

[៣៦] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១០។

[៣៧] ច្បាប់ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍ និងបណ្តាទោសប្រព្រឹត្តបទល្មើសផ្សេងៗទៀត ក្រឹត្យ-ច្បាប់លេខ ០២ ចុះថ្ងៃទី ១៥ ឧសភា ១៩៨០។ ។

[៣៨] កាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កញ្ញា ឧត្តម អរិយ ដែលបញ្ចប់ការសិក្សានៅសកលវិទ្យាល័យភូមិន្ទនីតិវិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាកម្មសិក្សាការីច្បាប់របស់ក្រុមមេធាវីការពារក្តីលោក អៀង សារី បានទៅសាលាដំបូងក្រុងភ្នំពេញ។ ឧត្តម អរិយ បាននិយាយជាមួយលោក ហេង សុភា ជានាយកក្រឡាបញ្ជី គាត់បានប្រាប់មកកញ្ញាវិញថា មានរឿងក្តីជាច្រើនរាប់ទាំងឃាតកម្ម ការធ្វើទារុណកម្ម ដែលមានតាំងពីឆ្នាំ ១៩៨២ រហូត ដល់ឆ្នាំ ១៩៩១។ តែកញ្ញាត្រូវផ្តល់សំបុត្រចេញដោយអវតក មានបញ្ជាក់ពីគោលបំណងនៃការស្រាវជ្រាវ និង ការប្រើប្រាស់សំណុំរឿងទាំងនេះ ទើបប្រធានតុលាការ នឹងសម្រេចថា

រឿងក្តី និងសាលក្រមទាំងនេះ អាចជួយដោយគ្មានមន្ទិលអ្វីទាំងអស់ដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចថាតើ ប្រព័ន្ធតុលាការមានដំណើរការនៅក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះ

---

ផ្តល់តាមសំណើ និង ថាតើកញ្ញាអាចទទួលបានបញ្ជីសំណុំរឿង និង គំរូនៃសាលក្រមដែរឬក៏អត់។ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ កញ្ញា ឧត្តម អរិយ បានទៅតុលាការដំបូងម្តងទៀត ដោយមានលិខិតដែលចុះហត្ថលេខា ដោយមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី កញ្ញា Nisha Valabhji ដែលបានស្នើសុំឱ្យផ្តល់នូវ “១- បញ្ជីរឿងក្តីព្រហ្មទណ្ឌដែលបានកើតក្នុងអំឡុងឆ្នាំ ១៩៧៩ និង ១៩៩១។ ប្រសិនបើបញ្ជីគ្រប់សំណុំរឿងទាំងអស់មិនអាចរកបាន នោះគំរូតំណាងមួយក៏អាចយកបានដែរ។ គំរូតំណាងនេះគួរតែជារឿងក្តី ឃាតកម្ម និងការធ្វើទារុណកម្ម ហើយប្រសិនអាចរកបាន គួរតែមានឈ្មោះ លេខសំណុំរឿង បទចោទ ចៅក្រម ព្រះរាជអាជ្ញា និង មេធាវី និង សេចក្តីសម្រេចចុងក្រោយ។ ២- គំរូ សាលក្រមខ្លះលើសំណុំរឿងមនុស្សឃាតក្នុងអំឡុងឆ្នាំ ១៩៧៩ ដល់ ១៩៩១”។ សូមមើលលិខិតពីអង្គភាពគាំពារការការពារក្តី ផ្ញើជូនប្រធានតុលាកាដំបូងក្រុងភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១។ កញ្ញា ឧត្តម អរិយ បាននិយាយជាមួយមន្ត្រីរដ្ឋបាលដែលបោះត្រាទទួលលិខិត ដោយបានប្រាប់កញ្ញាថា គួរតែត្រឡប់មកវិញនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ដើម្បីដឹងថា តើប្រធានតុលាការផ្តល់តាមសំណើ ឬក៏អត់។ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ កញ្ញា ឧត្តម អរិយ ក៏បានទៅក្រសួងយុត្តិធម៌ផងដែរ ហើយបានស្នើសុំនូវព័ត៌មានដូចគ្នា។ កញ្ញាបានប្រគល់លិខិត ពីអង្គភាពគាំពារការការពារក្តីជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលដូចគ្នានឹងលិខិតប្រគល់ជូនប្រធានតុលាការក្រុងដែរ។ កញ្ញា ឧត្តម អរិយ បាននិយាយជាមួយប្រធាននាយកដ្ឋានព្រហ្មទណ្ឌ គឺលោក ផូវ សំភី។ លោក ផូវ សំភី សុំឱ្យកញ្ញា ឧត្តម អរិយ ជួបជាមួយជំនួយការរបស់គាត់នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ កញ្ញាបានទូរស័ព្ទ និង និយាយជាមួយជំនួយការរបស់លោក ផូវ សំភី នៅក្រសួងយុត្តិធម៌។ ជំនួយការរបស់លោក ផូវ សំភី បានប្រាប់កញ្ញាថា គាត់មិនទាន់បានទទួលការអនុញ្ញាតណាមួយពីខុទ្ទកាល័យក្រសួងយុត្តិធម៌ ដើម្បីផ្តល់ព័ត៌មានដែលបានស្នើនោះទេ។ គាត់បានស្នើឱ្យកញ្ញាទាក់ទងគាត់ម្តងទៀត នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១។ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ កញ្ញា ឧត្តម អរិយ ក៏បានទៅ តុលាការដំបូង ខេត្តកណ្តាល ហើយបានស្នើសុំព័ត៌មានដូចគ្នា ដោយបានផ្តល់លិខិតពីអង្គភាពគាំពារការការពារក្តីជូនប្រធានតុលាការខេត្តកណ្តាល ដែលមានន័យដូចគ្នានឹងលិខិតទាំងពីរខាងលើ។ កញ្ញាបាននិយាយជាមួយក្រឡាបញ្ជី ដែលប្រាប់កញ្ញាថា ត្រូវតែជួបផ្ទាល់ជាមួយប្រធានតុលាការនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ដើម្បីទទួលបានសេចក្តីសម្រេច។ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ កញ្ញា ឧត្តម អរិយ បានទៅតុលាការខេត្តកណ្តាលម្តងទៀត។ កញ្ញាមិនអាចជួបប្រធានតុលាការ ដោយសារតែគាត់មានប្រជុំ។ កញ្ញាបានចាំប្រធានតុលាការមួយម៉ោងកន្លះមុននឹងចាកចេញ។ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ កញ្ញា ឧត្តម អរិយ បានត្រឡប់ទៅតុលាការក្រុងវិញ ហើយត្រូវបានប្រាប់ថា កញ្ញាអាចទទួលបានព័ត៌មានដែលបានស្នើខ្លះៗ ប្រសិនបើកញ្ញាត្រឡប់មកនៅថ្ងៃបន្ទាប់។ នាងបានធ្វើតាម។ ។ ប៉ុន្តែស្អែកឡើង នៅពេល អរិយ បានត្រលប់ទៅវិញ គាត់ត្រូវបានគេប្រាប់ថា ប្រធានតុលាការមិននៅ ដើម្បីផ្តល់អោយគាត់នូវអត្ថបទផ្លូវការនៃឯកសារដែលបានស្នើសុំឡើយ ហើយក្រឡាបញ្ជីនឹងមិនផ្តល់អោយគាត់នូវអត្ថបទមិនផ្លូវការឡើយ។ អ្នកនាង ឧត្តម អរិយ បានរង់ចាំប្រធានតុលាការត្រឡប់មកវិញ អស់ជាច្រើនម៉ោង ប៉ុន្តែប្រធានតុលាការមិនបានត្រលប់មកវិញឡើយគិតត្រឹមពេលដាក់ឯកសារនេះ។

សាលាដំបូង គួរតែប្រឹងប្រែងអោយអស់លទ្ធភាពដើម្បីបង្គាប់អោយតុលាការក្រុងភ្នំពេញ និង តុលាការជាតិដទៃទៀតដើម្បីអោយ តុលាការទាំងនេះអនុញ្ញាតអោយចូលពិនិត្យមើលកំណត់ត្រារបស់ខ្លួន។ នេះគឺជាភស្តុតាងល្អបំផុត ជាជាងស្តាប់ការអះអាងដែលគ្មានមូលដ្ឋានរបស់ កសព។ ជម្រើសម្យ៉ាងទៀតគឺ ប្រហែលជាត្រូវអោយចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង ធ្វើការជូនដំណឹងតាមលក្ខណៈតុលាការ ផ្អែកតាមការយល់ដឹង និងបទពិសោធន៍របស់ចៅក្រមទាំងនេះ ថាតុលាការទាំងឡាយនៅទូទាំងប្រទេសកម្ពុជា នៅក្នុងអំឡុងពេលពាក់ព័ន្ធដែលចោទជាបញ្ហានេះ (១៩៧៩-១៩៨១) បានកាត់សេចក្តីលើរឿងក្តីនានាដែលពាក់ព័ន្ធនឹងបទល្មើសដែលបានលើកឡើងខាងលើ។

១១. សៀវភៅរបស់សាស្ត្រាចារ្យ Michael Leifer ឆ្នាំ១៩៨១ បញ្ជាក់ថា ក្នុងខែ មិថុនា ឆ្នាំ ១៩៨០ វិទ្យុទីក្រុងភ្នំពេញបានផ្សាយអំពីការជំនុំជម្រះក្តីភ្នាក់ងារមិនមែនកុម្មុយនីស្តចំនួន ១៧នាក់ ដែលពាក់ព័ន្ធជាមួយនឹងមេដឹកនាំ Haem Kroesnea។ ពួកគេត្រូវបានកាត់ទោសដាក់ពន្ធនាគារពី ៣ឆ្នាំ ដល់ ២០ឆ្នាំ[៣៩]។ នៅក្នុងអត្ថបទមួយដែលសរសេរក្នុងឆ្នាំ១៩៨០ ប្រវត្តិវិទូ Michael Vickery សរសេរថា ៖

> អត្ថបទមួយនៅក្នុងកាសែតកម្ពុជាភ្នំពេញនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៨៨ អាចជាការបំភ្លឺមួយ។ នៅទំព័រ ១១ [មាន] បញ្ជីរឿងក្តីចំនួន ៦១ ដែលត្រូវបានរាយការណ៍ថាកំពុងរង់ចាំការសម្រេចពីតុលាការ។ រឿងក្តីចំនួន ៦១ ដែលកម្ពុជាបានរៀបរាប់ មានចាប់ពីបណ្តឹងរដ្ឋប្បវេណីតូចតាច ចំពោះការបរិហាកេរ្តិ៍ និងឆបោក រហូតដល់ករណីធ្ងន់ធ្ងរបំផុត ដូចជាអំពើមនុស្សឃាត និងការធ្វើទារុណកម្មពីសំណាក់ភ្នាក់ងារនគរបាល។ រួមមានទាំងរឿងក្តីជាច្រើន ដូចជា អំពើមនុស្សឃាត ការរំលោភលើផ្លូវភេទ ការរំលោភលើរាង្គកាយ និងការមិនសងបំណុល។ រឿងក្តីមួយគឺជាបណ្តឹងរបស់បុគ្គលម្នាក់ប្រឆាំងនឹងនគរបាល និងតុលាការខេត្តកណ្តាល ចំពោះការដោះលែងមនុស្សបីនាក់ដែលរងការចោទប្រកាន់ថាជាឃាតករ។ ជាការច្បាស់ណាស់ថា តុលាការក្នុងប្រទេសកម្ពុជាកំពុងដំណើរការអនុលោមតាមច្បាប់ ហើយថាបុគ្គលបានដាក់បណ្តឹងដោយស្ម័គ្រចិត្ត សូម្បីតែដាក់បណ្តឹង

---

[៣៩] សូមមើល Michael Leifer, *Kampuchea in 1980: The Politics of Attrition*, 1 ASIAN SURVEY 21, 98 (1981)។

ប្រឆាំងនឹងស្ថាប័នរដ្ឋ[៦០]។

១២. ក.ស.ព អះអាងថា ប្រព័ន្ធតុលាការមិនដំណើរការឡើយ ពីព្រោះ "នៅក្នុងអំឡុងពេលចាប់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩១ សាលាឧទ្ធរណ៍ក៏គ្មាន ហើយសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ក៏គ្មានដែរ។ នៅពេលដែលតុលាការកំពូលត្រូវបានបង្កើតឡើងដោយក្រឹត្យច្បាប់មួយនៅឆ្នាំ ១៩៨៥ ហើយដែលបានដំណើរការត្រឹមឆ្នាំ ១៩៨៧ តុលាការនេះមានសិទ្ធិអំណាចដែលមានកម្រិត ហើយមិនមានតួនាទីខាងតុលាការប្រកបដោយប្រសិទ្ធិភាពនោះទេ នៅមុនឆ្នាំ ១៩៩៤"[៦១]។ ក.ស.ព ពុំបានធ្វើការពន្យល់ថាហេតុអ្វីបានជាខ្លួនយល់ថា សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍គឺជាលក្ខខណ្ឌតម្រូវចាំបាច់ជាមុនចំពោះប្រព័ន្ធតុលាការដែលដំណើរការបាននោះ។ សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ គឺជាសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ដ៏សំខាន់ ប៉ុន្តែការពុំមានសិទ្ធិបែបនោះ ពុំមែនបង្ហាញថា ប្រព័ន្ធតុលាការមិនដំណើរការនោះឡើយ[៦២]។ លើសពីនេះទៀត ការអះអាងដែលថា តុលាការកំពូលមិន

---

[៦០] សូមមើល Michael Vickery, *The Rule of Law in Cambodia*, 14.3 CULTURAL SURVIVAL Q. (1990), *available at* http://www.culturalsurvival.org/publications/cultural-survival-quarterly/cambodia/rule-law-cambodia (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើល* MICHAEL VICKERY កម្ពុជា៖ នយោបាយ សេដ្ឋកិច្ច និងសង្គម 120 (Frances Pinter 1986) ដែល Vickery ថ្លែងថា "ការជំនុំជម្រះដែលមិនពាក់ព័ន្ធនយោបាយមួយ ត្រូវបានគេរាយការណ៍ ពាក់ព័ន្ធនឹងមនុស្ស ៥ នាក់ ដែលត្រូវបានចោទប្រកាន់នៅក្នុងខែ ឧសភា ១៩៨៦ អំពីបទប្លន់ និងនៅក្នុងករណីឃាតកម្មម័យ ដែលត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់ ១៨ឆ្នាំ និងរហូតដល់ទោសមួយជីវិតសម្រាប់ឃាតករ"។

[៦១] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

[៦២] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងពីសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ នៅក្នុង មាត្រា ១៤(៥) ប៉ុន្តែប្រទេសកម្ពុជាមិនបានឯកភាពតាម ICCPR នេះទេ រហូតដល់ខែ ឧសភា ឆ្នាំ ១៩៩២។ យោងតាម សៀវភៅដែលមានចំណេះដឹង និងព័ត៌មានទូលំទូលាយ Max-Planck ស្តីពីច្បាប់អន្តរជាតិសាធារណៈ: "ច្បាប់មនុស្សធម៌អន្តរជាតិមិនចែងអំពីសិទ្ធិដាច់ខាតក្នុងការធ្វើបណ្តឹង ឧទ្ធរណ៍នោះទេ...។ នៅពេលដែលរដ្ឋមួយចំនួនដែលមានការកើនឡើង បានចែងអំពីសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ <u>មាននិន្នាការមួយតម្រង់ទៅ</u>ខាងសិទ្ធិដែលជាទំនៀមទម្លាប់នេះ"។ ការជំនុំជម្រះក្តី ដោយយុត្តិធម៌ សិទ្ធិក្នុងការការពារជាអន្តរជាតិ នៅក្នុងសៀវភៅដែលមានចំណេះដឹង និងព័ត៌មានទូលំទូលាយ Max-Planck នៃនីតិអន្តរជាតិសាធារណៈ: ដែលអាចបើកមើលបាននៅ http://www.mpepil.com/sample_article?id=/epil/entries/law-9780199231690-e798&recno=16&#law-9780199231690-e798-titleGroup-37 (សេចក្តីបញ្ជាក់បន្ថែម)។ ចំណុច នេះបង្ហាញថា សិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ នឹងមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់ពីឆ្នាំ ១៩៧៩ នោះទេ រហូតដល់ពេលអាជ្ញាយុកាលបានផុតកំណត់។

បានដំណើរការនោះ ពុំមែនបង្ហាញថា តុលាការកំពូលមិនអាចដំណើរការបាននោះឡើយប្រសិនបើមាននរណាម្នាក់ប្តឹងសារទុក្ខនៅចំពោះមុខតុលាការកំពូលនេះ។ ដូចដែល ក.ស.ព បានបញ្ជាក់ តុលាការកំពូលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៥។ យោងតាមគេហទំព័ររបស់ អ.វ.ត.ក ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល អ.វ.ត.ក សោម សិរិវឌ្ឍ "បម្រើការងារជាចៅក្រមក្នុងតុលាការកំពូលប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៨៨។ មុនរយៈកាលនោះ លោកគឺជាមន្ត្រីក្នុងតុលាការកំពូលចាប់ពីឆ្នាំ ១៩៨៦ ដល់ឆ្នាំ ១៩៨៨ និងជាប្រធានស្តីទីនៃខុទ្ទកាល័យក្រសួងមហាផ្ទៃចាប់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៦"[៤៣]។ ក.ស.ព ទំនងជា អះអាង ដោយ *ភ័ន្តច្រឡំ* តួនាទីរបស់ចៅក្រម សោម សិរិវឌ្ឍ គឺជាការបំភាន់ ហើយគាត់ពុំមានតួនាទីពិតប្រាកដឡើយរយៈពេលជិត ៨ឆ្នាំ ក្នុងខណៈដែលគាត់ត្រូវបានជ្រើសតាំងឱ្យបម្រើការងារនៅក្នុងតុលាការកំពូល។

១៣. ក.ស.ព អះអាងថា "ច្បាប់អ៊ុនតាក់ (UNTAC) ឆ្នាំ ១៩៩២ ក៏បានចែងយោងយ៉ាងច្បាស់ទៅលើការខ្វះខាតមួយចំនួននៅក្នុងប្រព័ន្ធច្បាប់ដែលមានស្រាប់។ ឧទាហរណ៍ដូចជា មាត្រា ៧(២) បានចែងថា "ដោយមេធាវីមានចំនួនតិចតួចពេកនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលអន្តរកាលនេះ ជនជាតិខ្មែរឱ្យតែមានសញ្ញាប័ត្រមធ្យមសិក្សា អាចតំណាងឱ្យជនជាប់ចោទនៅក្នុងតុលាការបាន" ហើយ "ជនជាប់ចោទអាចពឹងពាក់សមាជិកគ្រួសារឱ្យធ្វើជាជំនួយផ្នែកច្បាប់បានទោះបីមានកម្រិតសិក្សាថ្នាក់ណាក៏ដោយ"[៤៤]។ ច្បាប់នេះអាចបង្ហាញពីភាពទន់ខ្សោយនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ប៉ុន្តែមិនបង្ហាញថា ប្រព័ន្ធតុលាការមិនដំណើរការនោះទេ។ ចុងចោទរឿងក្តីព្រហ្មទណ្ឌបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា ដូចនៅក្នុងយុត្តាធិការផ្សេងទៀតដែរ មានសិទ្ធិតំណាងខ្លួនឯង ទោះបីជាពួកគេមានកម្រិតសិក្សាថ្នាក់ណាក៏ដោយ។ នៅពេលពួកគេអនុវត្តសិទ្ធិនេះ វាមិនបង្ហាញថា ប្រព័ន្ធតុលាការមិនដំណើរការ ពីព្រោះពួកគេមិនត្រូវបានតំណាងដោយមេធាវីដែលមានការបណ្តុះបណ្តាលនោះឡើយ។ សិទ្ធិការពារ (ទោះបីតាមរយៈការការពារខ្លួនដោយខ្លួនឯង ឬតាមរយៈអ្នកការពារដែលតែងតាំងដោយតុលាការ) ត្រូវបានធានាដោយ ក្រិត្យ-ច្បាប់ លេខ ១ ក្នុងខែ ឧសភា ១៩៨០ ដែលនេះមានយូរយារមកហើយមុនច្បាប់អ៊ុនតាក់ឆ្នាំ ១៩៩២ទៅទៀត[45]។

[៤៣] សូមមើលគេហទំព័រ http://www.eccc.gov.kh/en/judicial-person/scc/som-sereyvuth។

[៤៤] សារណារបស់ ក.ស.ព កថាខណ្ឌ ១២។

[៤៥] ក្រិត្យ-ច្បាប់ លេខ ១ កំណត់អង្គការចាត់តាំងតុលាការប្រជាជនបដិវត្តគ្រប់ខេត្ត-ក្រុង ចុះថ្ងៃទី ១៥ ឧសភា ១៩៨០ មាត្រា ៧។ សិទ្ធិនេះក៏ត្រូវបានធានាផងដែរនៅក្នុងតុលាការយោធា ឆ្នាំ ១៩៨១ តាមរយៈ ក្រិត្យ-ច្បាប់ ៥ ស្តីពីការចាត់តាំងតុលាការយោធា ចុះថ្ងៃទី ១២ សីហា ១៩៨១ មាត្រា ៦។

១៤. ក.ស.ព អះអាងថា "ការខិតខំប្រឹងប្រែងដើម្បីបង្កើតឡើងនូវប្រព័ន្ធច្បាប់មួយដែលត្រឹមត្រូវតាមច្បាប់នៅក្នុងប្រទេសកម្ពុជា ក៏បានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ផងដែរ ដែលក្នុងនោះមានការប្ដេជ្ញាចិត្តមួយក្នុងការទទួលស្គាល់ និងគោរពតាមបទដ្ឋានសិទ្ធិមនុស្សទាំងឡាយដែលបានបង្កើតឡើងនៅក្នុងច្បាប់អន្តរជាតិ"[៤៦]។ ការប្ដេជ្ញាចិត្តរបស់ច្បាប់រដ្ឋធម្មនុញ្ញក្នុងការទទួលស្គាល់ និងគោរពសិទ្ធិមនុស្សមិនមែនជាលក្ខខណ្ឌកំណត់ថាមានប្រព័ន្ធតុលាការដែលកំពុងដំណើរការនោះទេ[៤៧]។ ទោះបីដូច្នោះក៏ដោយ ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ពិតជាបានឆ្លុះបញ្ចាំងនូវការប្ដេជ្ញាចិត្តក្នុងការទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ប៉ុន្តែវាមិនមែនជាច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាក្រោយឆ្នាំ ១៩៧៩ ដំបូងគេ ដែលទទួលស្គាល់ និងគោរពសិទ្ធិមនុស្សនោះទេ។ ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៧៩ ក៏មានមាត្រានានាដែលបង្ហាញពីការគោរពសិទ្ធិមនុស្សផងដែរ[៤៨]។ ជាសំខាន់ ច្បាប់រដ្ឋធម្មនុញ្ញនេះមានជំពូកមួយនិយាយពី "យុត្តាធិការ និងតុលាការ"[៤៩]។ ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៨៩ ក៏បានចែងពីការទទួលស្គាល់ និងការគោរពសិទ្ធិមនុស្សផងដែរ និងមាន ជំពូកមួយនិយាយពី "សាលាជម្រះក្តី និងអយ្យការ" [៥០]។

១៥. ក.ស.ព អះអាងថា កិច្ចប្រឹងប្រែងដ៏សំខាន់ ដើម្បីបង្កើតស្ថាប័ននៃអ្នកអាជីពច្បាប់ដ៏មានគុណវុឌ្ឍិ មួយក៏បានកើតឡើងផងដែរនៅក្នុងអំឡុងក្រោយឆ្នាំ ១៩៩១។ ក.ស.ព សំដៅដល់ការបង្កើត គណៈមេធាវីមួយ និងការបង្កើតកម្មវិធីបណ្តុះបណ្តាលរយៈពេល បួនឆ្នាំ ផ្នែកច្បាប់ ដោយកត់សម្គាល់ឃើញថា មានវគ្គបណ្តុះបណ្តាលច្បាប់រយៈពេលពីបីខែ ទៅប្រាំខែ មុនឆ្នាំ ១៩៨៩ និង កម្មវិធីបណ្តុះបណ្តាលច្បាប់រយៈពេល

---

[៤៦] សារណារបស់ ក.ស.ព កថាខណ្ឌ ១៤។

[៤៧] ច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេសអូស្ត្រាលីមានលក្ខណៈទន់ខ្សោយជាពិសេសផ្នែកសិទ្ធិមនុស្ស *សូមមើល* Adrienne Stone សិទ្ធិតាមច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេសអូស្ត្រាលី និងបញ្ហានៃ ការខ្វែង គំនិតបកស្រាយ ២៧ ស៊ីដនី L. REV. 29 (ឆ្នាំ ២០០៥) ហើយគេមិនបាន ទាមទារថា ប្រព័ន្ធតុលាការ របស់អូស្ត្រាលីមិនដំណើរការនោះទេ។

[៤៨] *សូមមើល* ឧទាហរណ៍ មាត្រា ៥ ដល់ ៨ និង ៣០ ដល់ ៤៤ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៧៩ អត្ថបទជាភាសាអង់គ្លេសមាននៅក្នុង *in* RAOUL M. JENNAR, ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា (ឆ្នាំ ១៩៥៣ ដល់ ១៩៩៣) ៩៣ ដល់ ៩៥ និង ៩៨ ដល់ ១០០ (White Lotus, 1995)។

[៤៩] ដូចខាងលើ ត្រង់ ១០៨ ដល់ ១០៩។

[៥០] ដូចខាងលើ ទំព័រ ១១៨ ដល់ ១២០ និង ១៣១ ដល់ ១៣២ (ដែលរៀបរាប់ពី មាត្រា ៣០ ដល់ ៤២ ដែលនៅក្នុងជំពូកដែលមានចំណងជើងថា "សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ" និងជំពូក VIII ស្តីពី "សាលាជម្រះក្តី និងអយ្យការ")។

២ឆ្នាំ ចាប់ពីឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩២[៥១]។ ក.ស.ព និយាយយោងលើអត្ថបទមួយរបស់ Dolores Donovan សម្រាប់សំណើនេះ[៥២]។ ប្រភពមួយទៀតដែល ក.ស.ព បានដកស្រង់នៅក្នុងផ្នែកផ្សេងនៃសារណារបស់ខ្លួន និងដែលនិយាយយោងលើ អត្ថបទផ្សេងមួយទៀតរបស់ Donovan នោះ[៥៣] បានលើកឡើងថា កម្មវិធីសិក្សាច្បាប់រយៈពេលបីខែ ត្រូវបានបង្កើតឡើងនាដើមឆ្នាំ ១៩៨២ រីឯកម្មវិធីបណ្តុះបណ្តាលយកសញ្ញាប័ត្ររយៈពេល ពីរឆ្នាំ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨៦[៥៤]។ អង្គហេតុដែលថាមានកម្មវិធីសិក្សាច្បាប់ ដែលធ្វើតាមទម្រង់នៅក្នុងអំឡុងពេលនេះ បង្ហាញថា ប្រព័ន្ធតុលាការបានដំណើរការហើយ។ កម្មវិធីរយៈពេលបួនឆ្នាំ ពិតជាមិនមែនជាលក្ខខណ្ឌកំណត់សម្រាប់ប្រព័ន្ធតុលាការកំពុងដំណើរការនោះទេ ពីព្រោះ រយៈពេលនេះជារយៈពេលដែលវែងជាងកម្មវិធីសិក្សាច្បាប់របស់រដ្ឋដែលមានការអភិវឌ្ឍន៍ ជាច្រើនដែលមានប្រព័ន្ធតុលាការកំពុងដំណើរការ។ លើសពីនេះទៀត មេធាវី និងចៅក្រមអាចបានទទួលការបណ្តុះបណ្តាលនៅបរទេស និងបានចូលរួមនៅក្នុងប្រព័ន្ធតុលាការកំពុងដំណើរការនៅ

---

[៥១] សារណារបស់ ក.ស.ព កថាខណ្ឌ ១៥។

[៥២] សម្រាប់ផ្នែកភាគច្រើន ចៅក្រមគឺជាមនុស្សដែលមានការសិក្សាខ្ពស់ ឬមានការសិក្សាថ្នាក់ ឧត្តមសិក្សាមួយឆ្នាំ ឬពីរឆ្នាំ ដែលបានបញ្ចប់ដោយជោគជ័យនូវវគ្គបណ្តុះបណ្តាលច្បាប់ រយៈពេលពី បីខែ ទៅប្រាំខែ ដែលបានផ្តល់ដោយវិទ្យាស្ថានរដ្ឋបាលសាធារណៈ និងច្បាប់ នៅចន្លោះឆ្នាំ ១៩៨២ និងឆ្នាំ ១៩៨៩"។ ដោយមិនបានយោងលើអំណាចណាមួយ ជើងទំព័ររបស់សេចក្តីថ្លែងការណ៍នេះ លើកឡើងថា "នៅឆ្នាំ ១៩៨៩ វិទ្យាស្ថានរដ្ឋបាលសាធារណៈ និងច្បាប់ បានចាប់ផ្តើមផ្តល់វគ្គបណ្តុះបណ្តាលច្បាប់រយៈពេលពីរឆ្នាំ។ អ្នកបញ្ចប់ការសិក្សា រយៈពេលពីរឆ្នាំនេះ ចំនួនបីបួននាក់ ត្រូវបានចាត់តាំងឲ្យទៅធ្វើការតាមក្រសួងរដ្ឋ ជាជាង ធ្វើការនៅតុលាការ។ នៅរដូវស្លឹកឈើជ្រុះឆ្នាំ ១៩៩២ វគ្គបណ្តុះបណ្តាលរយៈពេលបួនឆ្នាំបានចាប់ផ្តើម ជំនួសឲ្យកម្មវិធីរយៈពេលពីរឆ្នាំ។ កម្មវិធីរយៈពេលបួនឆ្នាំនៅក្នុងការសិក្សាច្បាប់នេះ បន្ទាប់មកនឹងក្លាយជាផ្នែកមួយនៃសាកលវិទ្យាល័យភ្នំពេញ។ អ្នកបញ្ចប់ការសិក្សានឹងទទួលបានសញ្ញាប័ត្រច្បាប់ ដែលសមមូលនឹងបរិញ្ញាប័ត្រច្បាប់"។ Dolores Donovan, ប្រទេសកម្ពុជា: កសាងប្រព័ន្ធច្បាប់ចាប់ពីចំណុចសូន្យ 27 INT'L LAWYER 445, 450, n. 20 (ឆ្នាំ ១៩៩៣)។ សូមកត់សម្គាល់ថា នេះមិនមែនជាជើងទំព័រដែល ក.ស.ព បានយកធ្វើជា សំអាងដើម្បីគាំទ្រសំណើរបស់ខ្លួននោះទេ (ជើងទំព័រ ១៧ នៃអត្ថបទ Donovan)។ ជើងទំព័រ ដែលបានរៀបរាប់ដោយ ក.ស.ព បង្ហាញថាបានដកស្រង់ដោយភ័ន្តច្រឡំ ពីព្រោះវាមិនបាននិយាយពីការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ។

[៥៣] Dolores Donovan, ប្រព័ន្ធច្បាប់កម្ពុជា: វិប្បដិភាពទូទៅ នៅក្នុងការកសាងប្រទេស កម្ពុជាឡើងវិញ: ធនធានមនុស្ស សិទ្ធិមនុស្ស និងច្បាប់ ៨១ ដល់ ៨៣ (ឆ្នាំ ១៩៩៣)។

[៥៤] Kathryn Nielson, ពួកគេសម្លាប់មេធាវី: ការកសាងប្រព័ន្ធតុលាការឡើងវិញនៅក្នុងប្រទេសកម្ពុជា ឯកសារ D22/6.9/5.26 ទំព័រ ៣។

ក្នុងប្រទេសកម្ពុជានៅពេលពួកគាត់វិលត្រលប់មកវិញ[៥៥]។ ទោះបីជាប្រទេសកម្ពុជាពុំមានកម្មវិធីបណ្តុះបណ្តាលច្បាប់យ៉ាងដូចម្តេចក៏ដោយ នេះមិនបង្ហាញថា ប្រព័ន្ធច្បាប់មិនអាចដំណើរការបាននោះឡើយ។

១៦. ប្រសិនបើទឡ្ហីករណ៍របស់ ក.ស.ព ត្រូវបានទទួលស្គាល់ នេះមានន័យថា នៅក្នុងអំឡុងឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ ទាំងមូល វាមិនអាចទៅរួចទេក្នុងការធ្វើឱ្យកើតមានការស៊ើបអង្កេត និងការចោទ ប្រកាន់នានា ឬយ៉ាងហោចណាស់ការស៊ើបអង្កេត និងការចោទប្រកាន់ ដែលនឹងត្រូវធ្វើឡើងដោយយុត្តិធម៌។ ប្រសិនបើចំណុចនេះជាការពិត នឹងមានន័យថា ចៅក្រមជាតិរបស់ អ.វ.ត.ក ជាច្រើន រូប បានចូលរួមនៅក្នុងការជំនុំជម្រះក្តីដែលមិនត្រូវបានគ្រប់គ្រងដោយវិធាននៃច្បាប់ ដែលជាភាពអយុត្តិធម៌ និងជាចំណុចដែលសិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពាន។ លទ្ធភាពនាពេលបច្ចុប្បន្នរបស់ចៅក្រមទាំងអស់នេះ នឹងចោទជាបញ្ហា (ឧទាហរណ៍ វានឹងបង្ហាញពីការខ្វះភាពសុចរិតរបស់តុលាការ ដែលកើតចេញមកពីការមិនឱ្យតម្លៃសិទ្ធិមនុស្សជាមូលដ្ឋានរួមជាមួយ នឹងបទដ្ឋាននានានៃការជំនុំជម្រះក្តីដោយយុត្តិធម៌) ចំពោះចៅក្រម សំណុំរឿង ០០២។ ដូចដែលបានកត់សម្គាល់ខាងលើ វានឹងមានន័យថែមទៀតថា រាល់សាលក្រមជំនុំជម្រះក្តីទាំងអស់ដែល បានចេញនៅក្នុងអំឡុងពេលនោះ ត្រូវតែពិចារណាថាទុកជាមោឃៈ។ ការបង្កើតប្រព័ន្ធតុលាការអធម្មានុរូបធ្វើឡើងដោយចៅក្រមអធម្មានុរូប។ គេអាចទាញការសន្និដ្ឋានបែបនេះយ៉ាងសមហេតុផល តាមរយៈសារណានានារបស់ ក.ស.ព ។

## ខ. សង្គ្រាមស៊ីវិលនឹងមិនពន្យារអាជ្ញាយុកាលនោះទេ

១៧. ក.ស.ព អះអាងថា "មានការបង្ហាញភស្តុតាងយ៉ាងច្បាស់នៅក្នុងទម្លាប់អនុវត្តរបស់ជាតិ និង អន្តរជាតិថាស្ថានភាពកំពុងមានសង្គ្រាមមួយដែលបានធ្វើឱ្យដំណើរការរបស់តុលាការត្រូវផ្អាក ទោះបីជាផ្ទៃក្នុង ឬមកពីខាងក្រៅក៏ដោយ ចាំបាច់គឺត្រូវតែពន្យារអាជ្ញាយុកាល"[៥៦]។ ក.ស.ព មិនបានបង្ហាញថា សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាបានធ្វើឱ្យដំណើរការរបស់តុលាការត្រូវផ្អាកនោះទេ។ ផ្ទុយទៅវិញ ក.ស.ព មានចេតនាបង្ហាញថា វានឹងមិនអាចទៅរួចទេក្នុងការចោទប្រកាន់ជនជាប់ចោទពិសេសទាំងនេះនៅពេល

---

[៥៥] ឧទាហរណ៍ យោងតាមគេហទំព័រ អ.វ.ត.ក ចៅក្រមអង្គជំនុំជម្រះសាលាដំបូង យ៉ា សុខន បានទទួលការបណ្តុះបណ្តាលនៅអតីតសហភាពសូវៀត ចៅក្រម ធូ មុនី បានទទួលការបណ្តុះបណ្តាលនៅប្រទេសអាល្លឺម៉ង់ និងចៅក្រម និល ណុន ទទួលការបណ្តុះបណ្តាលនៅប្រទេសវៀតណាម។

[៥៦] សារណារបស់ ក.ស.ព កថាខណ្ឌ ២៧។ (សេចក្តីបញ្ជាក់បន្ថែម)។

នោះ[៥៧]។ នេះមិនមែនជាការពិចារណាដែលពាក់ព័ន្ធនៅពេលសម្រេចលើបញ្ហាថា តើអាជ្ញាយុកាលអាចត្រូវបានព្យួរដោយសារតែសង្គ្រាមស៊ីវិលឬយ៉ាងណានោះទេ។ ការវិនិច្ឆ័យដែលអាចអនុវត្តបានគឺថាតើសង្គ្រាមមិនអាចឱ្យធ្វើការចោទប្រកាន់បាន តាមរយៈការរំខានដល់ដំណើរការនៃប្រព័ន្ធតុលាការ។

១៨. សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាមិនធ្វើឱ្យដំណើរការរបស់តុលាការត្រូវផ្អាកនោះទេ។ ដូចដែលបានពិភាក្សាខាងលើ ដំណើរការរបស់តុលាការបានបន្តពេញរយៈពេលនេះ។ ការប្រយុទ្ធគ្នា មិនបិតបេរនោះទេ និងបានកើតឡើងសំខាន់តែនៅក្នុងរដូវប្រាំងតែប៉ុណ្ណោះ[៥៨]។ លើសពីនេះទៀត ការប្រយុទ្ធគ្នានេះត្រូវបានកំណត់ព្រំដែនតែចំពោះតំបន់មួយចំនួន ដែលស្ថិតនៅក្បែរព្រំប្រទល់ថៃ[៥៩] តែប៉ុណ្ណោះ និងបានបន្ថយកម្លាំងនៅចន្លោះឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៨១ ដូចដែលបានបង្ហាញតាមរយៈ ការដកកងទ័ពចេញរបស់វៀតណាម[៦០] និងការរីកចម្រើននៃការចចារសន្តិភាពនៅក្នុងអំឡុងពេលនេះ[៦១]។

១៩. ក.ស.ព បានអះអាងថា "គោលការណ៍" ដែលថា សង្គ្រាមនឹងធ្វើឱ្យដំណើរការរបស់ តុលាការត្រូវផ្អាក អាចព្យួរអាជ្ញាយុកាលបាននោះ "ត្រូវបានគេពង្រីកទៅដល់បណ្តាប្រទេស ដែលប្រកាន់របបដែលប្រើអំណាចផ្តាច់ការគាបសង្កត់ ដែលនៅក្នុងនោះសិទ្ធិក្នុងការប្តឹងផ្តល់ តាមផ្លូវតុលាការអាចត្រូវបានរាំង"[៦២]។ ក.ស.ព មិនបានពន្យល់ថាតើ ក.ស.ព ពិចារណា ឃើញថា រដ្ឋាភិបាលដែលកាន់អំណាចនៅពេលនោះ គឺជារដ្ឋាភិបាលដែលប្រកាន់របបដែលប្រើអំណាចផ្តាច់ការគាបសង្កត់ដែលបានរាំងសិទ្ធិក្នុងការប្តឹងផ្តល់តាមផ្លូវតុលាការ ដែរឬទេឡើយ។ ក.ស.ព ពិតជាមិនបានបង្ហាញថា វាគឺដូច្នេះនោះទេ។ ក.ស.ព និយាយយោងតែលើសេចក្តីសម្រេចមួយរបស់តុលាការ Czech និងរឿងក្តីរបស់សហរដ្ឋអាមេរិកមួយចំនួន

---

[៥៧] ដូចខាងលើ កថាខណ្ឌ ១៧ ដល់ ១៨។

[៥៨] MICHAEL VICKERY, ប្រទេសកម្ពុជា ពីឆ្នាំ ១៩៧៥ ដល់ ១៩៨២ ៣១៣( Silkworm Books ឆ្នាំ ១៩៨៤ បោះពុម្ពលើកទី២ ឆ្នាំ ១៩៩៩)។

[៥៩] ដូចខាងលើ ត្រង់ ៣១៨។

[៦០] អ្នកប្រវត្តិវិទូ MICHAEL VICKERY បានសង្កេតឃើញថា ការជឿទុកចិត្តដែលកើនឡើងរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្ហាញឡើងតាមរយៈការដកកងទ័ពវៀតណាមប្រចាំឆ្នាំ ដែលគិតត្រឹមឆ្នាំ ១៩៨៣ ត្រូវបានដកចេញដោយឥតសង្ស័យ រដ្ឋបាលខ្មែរកើនឡើង ជាពិសេសក្រោយ សមាជបក្សលើកទីប្រាំ នៅឆ្នាំ ១៩៨៥ និងភាពធូរស្រាលផ្នែកនយោបាយបន្តិចម្តងៗនៅក្នុងប្រទេសកម្ពុជា ទោះបីជាតិចតួចក្តី។ ដូចខាងលើ ត្រង់ ៣១០។

[៦១] *សូមមើល* បុព្វកថារបស់ Ben Kiernan នៅក្នុង BENNY WIDYONO ការរាំនៅក្នុងស្រមោលៈ សីហនុ, ខ្មែរក្រហម និងអង្គការ សហប្រជាជាតិនៅក្នុងប្រទេស កម្ពុជា xx-xxiv (Rowman & Littlefield 2008)។

[៦២] សារណារបស់ ក.ស.ព កថាខណ្ឌ ២៨។

ប៉ុណ្ណោះ។ រឿងក្តី របស់សហរដ្ឋអាមេរិក គឺសុទ្ធតែជារឿងក្តីរដ្ឋប្បវេណីដែលបានរៀបចំឡើង ក្រោមច្បាប់ the Alien Tort Claims Act ("ATCA") ឬ TVPA។ រឿងក្តីទាំងអស់នេះមិនអាចប្រៀបធៀបទៅនឹងរឿងក្តីពេលនេះបានទេ ពីព្រោះរឿងក្តីទាំងនេះ៖ ១. គឺជារឿងក្តីរដ្ឋប្បវេណី មិនមែនជារឿងក្តី ព្រហ្មទណ្ឌ នៅពេលដែលសិទ្ធិ និងផលប្រយោជន៍ខុសៗគ្នាត្រូវតែយកទៅពិចារណា[៦៣]។ ២. ពាក់ព័ន្ធនឹងចំណុចពិសេសៗនៃការតាក់តែងបញ្ញត្តិច្បាប់ជាតិសហរដ្ឋអាមេរិក ដែលតុលាការសហរដ្ឋអាមេរិកបានរកឃើញថា តម្រូវឲ្យមានការពិចារណាអំពីគោលការណ៍ព្យួរអាជ្ញាយុកាល ដោយសមធម៌[៦៤]។ និង ៣. ពាក់ព័ន្ធនឹងស្ថានភាពទីកន្លែងដែលដើមបណ្តឹងរស់នៅ នៅក្នុងសហរដ្ឋអាមេរិក រីឯការស៊ើបអង្កេតដែលចាំបាច់នឹងមិនអាចធ្វើបាននៅក្នុងប្រទេសកំណើតរបស់គាត់នោះទេ ឬក៏ចុងចោទមានអភ័យឯកសិទ្ធចាកផុតពីការចោទប្រកាន់នៅក្នុងប្រទេសកំណើតរបស់គាត់[៦៥]។

---

[៦៣] "The TVPA និង the [ATCA] បានចែករំលែកនូវគោលបំណងរួមនៅក្នុងការការពារ សិទ្ធិមនុស្សជាអន្តរជាតិ។ The TVPA ផ្តល់ការជួយសង្គ្រោះជនរងគ្រោះដោយសារការធ្វើ ទារុណកម្ម 28 U.S.C. § 1350 រីឯ the [ATCA] ជួយជនបរទេសឲ្យដាក់ពាក្យបណ្តឹង ទៅតុលាការសហព័ន្ធ ដើម្បីស្នើសុំសំណងពីកំហុសស៊ីវិល "ដែលបានប្រព្រឹត្តឡើងរំលោភ លើច្បាប់របស់ប្រជាជាតិ" 28 U.S.C. § 1350។ ច្បាប់លក្ខន្តិកៈទាំងពីរប្រើប្រាស់បណ្តឹង រដ្ឋប្បវេណីជាយន្តការក្នុងការជម្រុញគោលបំណងរួមគ្នារបស់ច្បាប់ទាំងពីរ ហើយច្បាប់ ទាំងពីរអាចត្រូវបានរកឃើញនៅទីកន្លែងតែមួយដែលស្ថិតនៅក្នុងក្រមសហរដ្ឋអាមេរិក"។ រឿងក្តី *Chavez* តទល់នឹង *Carranza*, 559 F.3d 486, 492 (6th Cir. Tenn. 2009)។

[៦៤] ការព្យួរអាជ្ញាយុកាលដោយសមធម៌ គឺជា "ទ្រឹស្តីដែលអាជ្ញាយុកាលនឹងមិនរារាំងការទាមទារ នោះទេ ប្រសិនបើដើមចោទមិនបានរកឃើញព្យសនកម្មនោះទេរហូតក្រោយពេលអាជ្ញាយុកាលផុតកំណត់ ទោះបីខំប្រឹងប្រែងរកយ៉ាងណាក៏ដោយ"។ វចនានុក្រម BLACK'S LAW DICTIONARY (បោះពុម្ពផ្សាយលើកទី៧ ឆ្នាំ ១៩៩៩) "យុត្តាធិការសម្រាប់ការអនុវត្តទ្រឹស្តីនៃការព្យួរអាជ្ញាយុកាលដោយសមធម៌ ក្រោមច្បាប់ the TVPA អនុវត្តស្មើភាពគ្នាចំពោះការ ទាមទារដែលធ្វើ ឡើងក្រោមច្បាប់ the [ATCA] ។ សភាបានផ្តល់ការណែនាំយ៉ាង ច្បាស់លាស់ ពាក់ព័ន្ធនឹងការអនុវត្តការព្យួរអាជ្ញាយុកាលដោយសមធម៌ក្រោមច្បាប់ the TVPA ។ the TVPA "អំពាវនាវឲ្យមានការពិចារណាលើគោលការណ៍នៃការព្យួរអាជ្ញាយុកាលដោយសមធម៌ទាំងអស់ ដោយគណនារយៈពេលអាជ្ញាយុកាលនេះជាមួយនឹងទស្សនៈមួយដែលផ្តល់យុត្តិធម៌ ចំពោះសិទ្ធិរបស់ដើមចោទ"។ រឿងក្តី *Chavez* តទល់នឹង *Carranza*, 559 F.3d 486, 492 (6th Cir. Tenn. 2009)។

[៦៥] *សូមមើល* រឿងក្តី *Jeav* តទល់នឹង *Dorelien*, 431 F.3d 776, 780 (11th Cir. Fla. 2005) ។ រឿងក្តី *Arce* តទល់នឹង *Garcia*, 434 F.3d 1254, 1262 (11th Cir. Fla. 2006)។ រឿងក្តី *Forti* តទល់នឹង *Suarez-Mason*, 672 F. Supp. 1531, 1550 (N.D. Cal. 1987)។ រឿងក្តី *Hilao* តទល់នឹង *Estate of Marcos*, 103 F.3d 767, 773 (9th Cir. Haw. 1996)។ រឿងក្តី *Cabello* តទល់នឹង *Fernandez-Larios*, 402 F.3d 1148, 1155 (11th Cir. Fla. 2005)។ រឿងក្តី *Chavez* តទល់នឹង *Carranza*, 559 F.3d 486, 493 (6th Cir. Tenn. 2009)។

២០. ក.ស.ព អះអាងថា “គោលការណ៍អន្តរជាតិ” ដែលអាជ្ញាយុកាលត្រូវបានពន្យារ ដោយហេតុថាមាន “សង្គ្រាមរវាងមហាអំណាច” ចំនួនពីរនោះ គឺអាចអនុវត្តផងដែរនៅទីនេះ ដោយសារតែសង្គ្រាម ស៊ីវិល នៅក្នុងប្រទេសកម្ពុជា[៦៦]។ គោលការណ៍ដែលថា អាជ្ញាយុកាលមិនអនុវត្តរវាងរដ្ឋពីរដែលមានសង្គ្រាម នឹងគ្នានោះ មិនអាចអនុវត្តបានចំពោះស្ថានភាពសង្គ្រាមស៊ីវិលឡើយ។ លើសពីនេះទៀត ដូចដែល បានពន្យល់រួចហើយ សង្គ្រាមនៅក្នុងប្រទេសកម្ពុជាមិនប៉ះពាល់ដល់មួយផ្នែកធំនៃប្រទេសនោះទេ និងជា សំខាន់ មិនបង្អាក់ដំណើរការរបស់ប្រព័ន្ធតុលាការឡើយ។

២១. ការអះអាងរបស់ ក.ស.ព ដែលថា ជនជាប់ចោទ “នៅតែបន្តធ្វើជាមេដឹកនាំឲ្យកងកម្លាំង ប្រឆាំងរបប របស់ខ្មែរក្រហមដែលសកម្មមិនព្រមចុះចូលជាមួយនឹងដែនសមត្ថកិច្ចរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជា មានិតកម្ពុជា (ដែលក្រោយមកជា រដ្ឋកម្ពុជា )” និងថា “អង្គការសហប្រជាជាតិបានបន្តទទួលស្គាល់ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ថាជាប្រធានធម្មានុរូប [ប្រមុខរដ្ឋពេញច្បាប់]” មិនបង្ហាញថា ដំណើរការ របស់តុលាការត្រូវបានបង្អាក់នោះទេ ដូចនេះ ការចោទប្រកាន់គឺជា “អលទ្ធភាព ជារូបវ័ន្ត ខាងនយោបាយ និងការអនុវត្ត”[៦៧]។

២២. ពាក់ព័ន្ធនឹងលទ្ធភាពជារូបវ័ន្ត និងការអនុវត្តដែលបានលើកឡើងដើម្បីធ្វើការចោទប្រកាន់ជនជាប់ចោទ គួរតែមានការរំលឹកថា ច្បាប់កម្ពុជាបានអនុញ្ញាតឲ្យមានសវនាការ *ដោយកំបាំងមុខ* នៅក្នុងអំឡុងពេល នេះ[៦៨]។ សវនាការ *ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតឲ្យធ្វើនៅក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ននេះ[៦៩] ដូចនៅ ក្នុងតុលាការផ្សេងទៀតដែរ[៧០]។ ប្រសិនបើរដ្ឋាភិបាលមានបំណងបង្កើត កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង ជនជាប់ចោទចំពោះការរំលោភច្បាប់ជាតិ មុនពេលផុតអាជ្ញាយុកាលដែលអាចអនុវត្តបាន រដ្ឋាភិបាលអាច

---

[៦៦] សារណារបស់ ក.ស.ព កថាខណ្ឌ ២៩។

[៦៧] ដូចខាងលើ កថាខណ្ឌ ១៦។

[៦៨] *សូមមើល* ក្រិត្យលេខ ២ ច្បាប់ស្ដីពី ការចាត់តាំងអង្គការតុលាការ និងអយ្យការ ចុះថ្ងៃទី ១០ កុម្ភៈ ១៩៨២ មាត្រា ១១។ ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៨៩ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ មាត្រា ៣៨។ សវនាការ ដោយកំបាំងមុខ បានកើតឡើងមុនឆ្នាំ ១៩៨២ ផងដែរ ដូចដែលបានបង្ហាញ តាមរយៈការជំនុំជម្រះក្ដី ប៉ុល ពត និង អៀង សារី ឆ្នាំ ១៩៧៩ ដែលត្រូវបានធ្វើឡើងដោយកំបាំងមុខ អនុលោមតាមច្បាប់ស្ដីពីការបង្កើតតុលាការបដិវត្តន៍របស់ប្រជាជន នៅទីក្រុងភ្នំពេញ ដើម្បីកាត់សេចក្ដីបទ ប៉ុល ពត, អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៩។ មាត្រា ៦ ដល់ ៧។

[៦៩] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣៣។

[៧០] *សូមមើល* ច្បាប់លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ មាត្រា ២២។

ធ្វើដូច្នេះបាន។ ប្រព័ន្ធតុលាការកំពុងដំណើរការ និងអាចធ្វើការស៊ើបអង្កេតដែលចាំបាច់នានាបាន។ ក.ស.ព មិនបានបង្ហាញថា រដ្ឋាភិបាល អសមត្ថភាពក្នុងការបង្កើតកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* នោះទេ។

២៣. ការខកខានរបស់រដ្ឋាភិបាលក្នុងការបង្កើតកិច្ចដំណើរការនីតិវិធី មិនអាចពន្យល់បានតាមរយៈ អលទ្ធភាពជារូបវ័ន្ត ឬការអនុវត្តបានទេ។ រដ្ឋាភិបាល មិនថាដោយសារមូលហេតុអ្វីនោះទេ បានសម្រេចចិត្តមិនបង្កើតកិច្ចដំណើរការនីតិវិធីនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធភាពបីយ៉ាងបានលេចឡើងរួចជាស្រេច៖ ១. រដ្ឋាភិបាលបានពិចារណាពីកិច្ចដំណើរការនីតិវិធីកាលពីមុនរបស់ខ្លួនថាមានសុពលភាពនៅក្នុងរឿងក្តីរបស់លោក អៀង សារី។ ២. រដ្ឋាភិបាលមិនពិចារណាឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្ត ការញុះញង់ ការបញ្ជា ឬការជួយ និងជម្រុញឱ្យមានការសម្លាប់មនុស្ស ការធ្វើទារុណកម្ម ឬការធ្វើទុកបុកម្នេញផ្នែកសាសនា ក្រោម ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នោះទេ។ ឬក៏ ៣. មិនដូច្នេះទេ រដ្ឋាភិបាលខ្វះចេតនាផ្នែកនយោបាយ ក្នុងការបន្តការកាត់សេចក្តីឱ្យដល់ទីបញ្ចប់។

២៤. ក.ស.ព អះអាងថា ការចោទប្រកាន់មិនអាចទៅរួចទេផ្នែកនយោបាយ ពីព្រោះអង្គការសហប្រជាជាតិបានទទួលស្គាល់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ("DK")។ ការអះអាងនេះមិនត្រូវបានគាំទ្រ និងមិនត្រឹមត្រូវទេ។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ("PRK") មានសង្គ្រាមជាមួយ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ។ ប្រសិនបើការទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពីសំណាក់អង្គការសហប្រជាជាតិ មិនហាមឃាត់មេដឹកនាំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាកុំឱ្យធ្វើសង្គ្រាមជាមួយនឹងមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យទេនោះ គេលំបាកនឹងអះអាងថា ការទទួលស្គាល់នេះ នឹងរារាំងមេដឹកនាំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនឱ្យធ្វើការចោទប្រកាន់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ។ ពុំមានការបង្ហាញថា រដ្ឋាភិបាលបានទប់ស្កាត់មិនឱ្យមានការចោទប្រកាន់ដោយសារតែការទទួលស្គាល់របស់អង្គការសហប្រជាជាតិឡើយ។ ទោះបីជាវាដូច្នេះក្តី ការខ្វះឆន្ទះនយោបាយក្នុងការចោទប្រកាន់មិនបង្ហាញថា ប្រព័ន្ធតុលាការមិនដំណើរការនោះទេ។ សូមពិចារណាលើសំណុំរឿង ០០៣ នៅ អ.វ.ត.ក។ ដូចដែលអ្នកសង្កេតការណ៍របស់ អ.វ.ត.ក ជាច្រើនរូបបានកត់សម្គាល់ វាអាចមិនឈានដល់ការជំនុំជម្រះក្តីបានទេ ពីព្រោះមានការខ្វះឆន្ទះនយោបាយ (ដូចជា អ.វ.ត.ក មិនមានឯករាជ្យពីការជ្រៀតជ្រែកផ្នែកនយោបាយ រឺងចៅក្រមទាំងអស់មិនមែនសុទ្ធតែឯករាជ្យនោះទេ) សម្រាប់ រឿងក្តីដែលត្រូវដំណើរការ[៧១]។

---

[៧១] *សូមមើល ជាឧទាហរណ៍ ការវិវឌ្ឍន៍ថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* OPEN SOCIETY JUSTICE INITIATIVE មិថុនា ២០០១១ ទំព័រ៣ "សេចក្តីថ្លែងការណ៍មួយចំនួន [ដោយសហព្រះរាជអាជ្ញាកម្ពុជា] បង្កើតអោយមានចម្ងល់ថាតើ ការស៊ើបសួរដែលមិនចុះដល់កន្លែង [សម្រាប់រឿងក្តី ០០៣ និង ០០៤] ត្រូវបានកាត់តំរិមដោយផ្តល់នូវការបិតបាំងផ្លូវច្បាប់សម្រាប់ការបដិសេធដែលសម្រេចដោយមូលហេតុនយោបាយទៅលើរឿងក្តីដែលមានលក្ខណៈនយោបាយទាំងនេះ"។ សូមមើល អ៊ូ វីរៈ

ចំណុចនេះអាចបង្ហាញនូវបញ្ហាធ្ងន់ធ្ងរនានាដែលស្ថិតនៅក្នុង អ.វ.ត.ក ដែលនៅទីបំផុត អាចប៉ះពាល់ដល់កេរដំណែលរបស់ អ.វ.ត.ក ប៉ុន្តែវាមិនបង្ហាញថា អ.វ.ត.ក មិនដំណើរការនោះទេ។

## គ. ដោយសារតែគ្មានលក្ខខណ្ឌដែលបានរារាំងមិនឱ្យចោទប្រកាន់ជនជាប់ចោទ អាជ្ញាយុកាលមិនត្រូវបានព្យួរ និងបានផុតកំណត់មុនពេលត្រូវបានពន្យារ

២៥. ក.ស.ព អះអាងថា អាជ្ញាយុកាលអាចត្រូវបានព្យួរ ប្រសិនបើអលទ្ធភាពនៃការអនុវត្តបណ្តាលមកពីកំហុស ឬការបន្លំរបស់ជនជាប់ចោទ[៧២]។ ក.ស.ព បានសំអាងលើរឿងក្តីរដ្ឋប្បវេណីមួយមកពី Louisiana ដែលជារឿងក្តីរដ្ឋប្បវេណីបារាំង និងអត្ថបទពិនិត្យមើលច្បាប់ឡើងវិញស្តីពីភាពសុចរិតនៅក្នុងការចចារធ្វើកិច្ចសន្យា[៧៣]។ ចំណុចនេះមិនគ្រប់គ្រាន់ទេក្នុងការបង្ហាញថា ច្បាប់កម្ពុជាតម្រូវឱ្យមានការព្យួរអាជ្ញាយុកាលនៅក្នុងរឿងក្តីពេលនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ទឡ្ហីករណ៍នេះមិនចាំបាច់លើកឡើងនោះទេ ពីព្រោះវាត្រូវបានពន្យល់រួចហើយថា ពុំមានអលទ្ធភាព នៃការអនុវត្តក្នុងការចោទប្រកាន់ជនជាប់ចោទនៅក្នុងអំឡុងពេលអាជ្ញាយុកាលដែលច្បាប់បានចែងនោះទេ។ ប្រព័ន្ធតុលាការបានដំណើរការ សង្គ្រាមស៊ីវិលមិនបានបញ្ឈប់ដំណើរការរបស់តុលាការនោះទេ រីឯរដ្ឋាភិបាលអាចអនុវត្តការចោទប្រកាន់ដោយកំបាំងមុខបាន ប្រសិនបើរដ្ឋាភិបាលចង់ធ្វើដូច្នេះមែន និងប្រសិនបើរដ្ឋាភិបាលយល់ឃើញខ្លួនឯងថាមិនអាចចាប់ជនជាប់ ចោទបាន។ មេធាវីការពារក្តីជំទាស់នឹងការអះអាងរបស់ ក.ស.ព ដែលថា ជនជាប់ចោទបានស្វែងរក "ការលុបបំបាត់ចៅក្រម មេធាវី និងអ្នកអាជីពច្បាប់ដទៃទៀត ព្រមទាំងបញ្ញាជន ដែលត្រូវបានគេគិតថាជាខ្មាំងវណ្ណៈ" ឬមិនថាតាមមធ្យោបាយណាទេ ជនជាប់ចោទត្រូវទទួលខុសត្រូវដោយផ្ទាល់

---

*Open Letter to Tribunal's Clint Williamson* កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ "ការអភិវឌ្ឍថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា (អ.វ.ត.ក) ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ គឺជាមូលហេតុដែលនាំឱ្យមាន ការព្រួយបារម្ភធ្ងន់ធ្ងរ និងចោទជាបញ្ហាថាតើអង្គការសហប្រជាជាតិយល់ព្រមតាមសំណើ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ចប់ការងាររបស់ អ.វ.ត.ក នៅពេលបញ្ចប់សំណុំរឿង ០០២ ដែរឬទេ"។

[៧២] សារណារបស់ ក.ស.ព កថាខណ្ឌ ៣១។

[៧៣] ដូចខាងលើ កំណត់សម្គាល់ ៨៩។

ចំពោះកង្វះខាតនៃប្រព័ន្ធតុលាការបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ[៧៤]។ ចំណុចនេះនឹងក្លាយជាបញ្ហាសម្រាប់សវនាការ។

III. **សំណូមពរដែលបានស្នើសុំ**

**ហេតុដូច្នេះ** តាមហេតុផលដូចដែលបានរៀបរាប់នៅក្នុងចម្លើយតបនេះ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា យល់ឃើញថា មាត្រា ៣ ថ្មី មិនអាចអនុវត្តនៅ អ.វ.ត.ក បានទេ។

សូមអង្គបុរេជំនុំជម្រះមេត្តាទទួលនូវការគោរពដ៏ស្មោះត្រង់អំពីយើងខ្ញុំ។

| អាង ឧត្តម | Michael G. KARNAVAS |
|---|---|

សហមេធាវីរបស់លោក អៀង សារី

| ផាត់ ពៅស៊ាង | Diana ELLIS |
|---|---|

សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ

| សុន អរុណ | Michiel PESTMAN | Victor KOPPE |
|---|---|---|

សហមេធាវីរបស់លោក នួន ជា

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១១

[៧៤] ដូចខាងលើ កថាខណ្ឌ ៣២។